
សៀវភៅគតិលោក

ភាគទី២



សុត្តន្តប្រីជា ឥន្ទ

១៨៥៩ - ១៩២៤

CHANBOKEO.COM
ឆែន បន្ទុះឈាំ

ពាលទវត្ត

អន្តេវាសិកឆ្លើយតបគ្រូទីញ្ញទៀតថា សូមទានព្រះតេជព្រះគុណ ទីអំពីពុតពាលដែលវាតែងប្រព្រឹត្តបៀតបៀនអ្នកស្រុកនោះ តើដោយហេតុយ៉ាងណាខ្លះ?។

គ្រូប្រាប់ថា ឯមនុស្សពាលនោះកាលវាបានឱកាសនឹងបៀតបៀនអ្នកស្រុកនោះ ព្រោះហេតុអ្នកស្រុកជាបច្ច័យ គឺថាពាលនោះគយឃ្លាំចាំស្តាប់ហេតុរបស់អ្នកស្រុកបាន ព្រោះអ្នកខ្លះបានជម្ងឺឈឺចាប់ជាក្តីរំខាន ហើយក៏មានចិត្តប្រាថ្នា ចង់បានគ្រូពេទ្យនឹងរកគ្រាគោគ អ្នកខ្លះត្រូវការចង់បានខ្ទុំកំដរនឹងធ្វើស្រែធ្វើចំការ អ្នកខ្លះត្រូវការឈើព្រៃនឹងធ្វើផ្ទះ អ្នកខ្លះចង់បានគ្រឿងមាសប្រាក់ជាដើម សេចក្តីត្រូវការរបស់អ្នកស្រុកនោះ ក៏ជាហេតុនឹងកើតទៅដល់មនុស្សពាលៗ នោះវាដឹងថាភូមិនោះផ្ទះនោះត្រូវការវត្ថុនោះៗទើបវាប្រកបការតាមផ្លូវ ដែលពួកអ្នកស្រុកប្រាថ្នានោះឯង មនុស្សក្នុងលោកនេះកាលបើមានសេចក្តីប្រាថ្នានូវវត្ថុអ្វីៗ អារម្មណ៍នោះប្រាថ្នាប្រព្រឹត្តទៅរឿយៗលុះមានអ្នកណាមកនិយាយត្រូវត្រង់វត្ថុដែលខ្លួនប្រាថ្នាប្រាថ្នានេះ ក៏កើតសេចក្តីគាប់ចិត្ត១ រំពេច

ទៅដោយសារអារម្មណ៍នោះចាប់មកហើយរឿយៗ ម្ល៉ោះហើយក៏ភ្លើតភ្លើនទៅ ជាផ្លូវឲ្យមនុស្សពាលបានឱកាសចូលយាយីបានដូចនិទានចៅទ្បុច ធ្វើឲ្យមនុស្សពាលបញ្ចោតយកប្រាក់១០០បាទទៅបាន។

រឿងចៅទ្បុចនឹងចៅប្រាក់

ឯរឿងចៅទ្បុកនោះថាកាលនោះមានមនុស្សពាលម្នាក់ឈ្មោះចៅប្រាក់នៅស្រុកបាត់ដំបង ចៅប្រាក់នោះជាខ្ទុំលោកសុភាទេស ថ្លៃខ្លួនវា២០០បាទ លុះនៅយូរមកក៏លោកសុភាទេស ប្រើឲ្យទៅឃ្វាលក្របីនឹងក្មេងម្នាក់ទៀត ឃ្វាលនៅឯវាលស្រែក្រៅចៅប្រាក់នោះលុះឃ្វាលបន្តិចទៅ ក៏និយាយនឹងក្មេងនោះថា យើងនៅឃ្វាលក្របីទាំងពីរនាក់នេះយើញ្ជាព្រួយការពេកណាស់ ទិសយក្របី១ក៏ដូចជាក្របី១០ក៏យប់ដូចគ្នា បើដូច្នេះអញគិតទៅយើញ្ជាថានៅឃ្វាលទាំងពីរនាក់នេះ ក៏ជាការព្រួយសំបាកណាស់ ព្រោះពុំមានអ្នកណានឹងរកអាហារសែ្បងបញ្ជូនមកឲ្យ បើដូច្នេះចូរឯងនៅឃ្វាលតែម្នាក់ឯងចុះ អញនឹងទៅរកស៊ីឈ្មួលពាត់គេ ក្រែងបានប្រាក់កាស ក៏នឹងទិញសែ្បងមកលែ្បងចិញ្ចឹមគ្នា ទៅតាមជាតិអ្នកកំសត់កុំឲ្យអត់

ឃ្លានពេកឯក្មេងនោះ លុះបានស្តាប់ចៅប្រាក់ថាដូច្នោះក៏ព្រមតាម ទើបទទួលការឃ្វាលក្របីនោះនៅម្នាក់ឯង បើកឲ្យចៅប្រាក់ទៅរកស៊ីឈ្នួលគេឯភូមិស្ទឹង ឯចៅប្រាក់ដើរមករកធ្វើការស៊ីឈ្នួលគេក៏រកធ្វើពុំបាន ដើរទៅៗបានជួបនឹងមនុស្សពាលម្នាក់ ឈ្មោះនាយជាៗ នោះជាតិជាជ្លាចាមបានសូមគ្នាជាមិត្តភក្តិ នាំគ្នាទៅសំណាក់នឹងផ្ទះនាយអ៊ូជាបងធម៌នាយជា លុះថ្ងៃ១នាយជានិយាយនឹងចៅប្រាក់ថា យើងនឹងគិតប្រកបការរកស៊ីតាមគេអ្នកស្រុកនេះឃើញជាពុំបាន ព្រោះពុំមានដើមទុនអ្វីសោះ បើដូច្នោះយើងគិតលក់ខ្លួនថ្លៃចែកគ្នា ឯចៅប្រាក់ឆ្លើយថាត្រូវមែនហើយសំឡាញ់គឺត នោះបើដូច្នោះសំឡាញ់ឯងធ្វើជានាយចៅហ្វាយអញ្ចឹងធ្វើជាខ្ញុំ ឯងយកអញ្ចឹងទៅលក់ចុះ នាយជាឮចៅប្រាក់ព្រមចិត្តដូច្នោះ ក៏ត្រេកអរពេកណាស់ ទើបនាំគ្នាទៅឯភូមិចុងក្តុល ដើរស្តាប់ហេតុអ្នកស្រុក គឺផ្ទះណាត្រូវការចង់បានតួរាង លុះស៊ើបហេតុទៅក៏ដឹងថា ផ្ទះចៅឡុកត្រូវការរកមនុស្សនឹងច្រូតស្រូវ ទើបចៅប្រាក់និយាយថាមែនហើយអ្នកឡុចនោះគាត់ក៏ស្គាល់អញ្ចឹងដែរ ព្រោះពីដើមអញ្ចឹងធ្លាប់នៅជិតខាងគាត់ ប្រសិនជាយើងទៅរកប្រាក់គាត់ គង់

គាត់លោះយើងមិនខាន ឯនាយជាក៏យល់តាមទើបនាំគ្នាទៅកាន់ផ្ទះចៅឡុច ដល់ហើយក៏ទៀងទៅសំពះសួរចៅឡុចតាមការសមគួរ ឯចៅឡុចក៏សួរថា អើជីប្រាក់ឯងសព្វថ្ងៃនេះទៅនឹងអ្នកឯណា ចៅប្រាក់ក៏ឆ្លើយថា បាទខ្ញុំសព្វថ្ងៃនេះនៅនឹងអ្នកជាដែលមកផងនេះឯង ឥឡូវនេះគាត់ថានឹងទៅស្រុកគាត់ គឺស្រុកបន្ទាយភ្នំពេញវិញ គាត់នឹងយកខ្ញុំបាទទៅផង ខ្ញុំបាទពុំចង់ទៅព្រោះស្រុកឆ្ងាយ គឺរកប្រាក់ជូនគាត់វិញ គាត់ក៏ព្រមតាមចិត្ត ហេតុនេះខ្ញុំបាទចូលមករកប្រាក់អ្នក សូមឲ្យអ្នកមេត្តាលោះខ្ញុំបាទផងឯចៅឡុចបានស្តាប់ពាក្យចៅប្រាក់ដូច្នោះ ក៏សួរទៅនាយជាថាអើអ្នកឯងជានាយជីប្រាក់ លោះគ្នាមកថានឹងនៅស្រុកនេះហើយ ហេតុដូចម្តេចក៏វិលទៅស្រុកបន្ទាយភ្នំពេញវិញ នាយជាក៏តបថា កាលដើមខ្ញុំបាទថាប្រុងនឹងនៅក្នុងស្រុកនេះពិតហើយ បានជាលោះជីប្រាក់នេះដើម្បីជាកំប្លាំងជួយរកទទួលទាន ឥឡូវនេះបងខ្ញុំបាទមានសំបុត្រប្រាប់មកថា ម្តាយខ្ញុំបាទឯស្រុកនាយនោះមានជម្ងឺឈឺជាទម្ងន់ ឲ្យខ្ញុំបាទវិលទៅស្រុកជាឆាប់ ហេតុនេះខ្ញុំបាទទាល់តំនិតប្រាជ្ញាចំណែកជីប្រាក់គេក៏មិនព្រមទៅជាមួយផង គេថារកប្រាក់ជូនខ្ញុំបាទវិញខ្លួនខ្ញុំបាទ

ម្នាក់ឯងបានជាដើរតាមមកផងនេះ ឯចៅប្រាក់ឆ្លើយសារទៅវិញ
ថា អ្នកចូរអាណិតខ្ញុំបាទផង បើអ្នកមិនសង្គ្រោះខ្ញុំបាទហើយ
ខ្លួនខ្ញុំបាទឃើញជាគេយកទៅស្រុកបន្ទាយមិនខានទៀយឯចៅ
ឡុចក៏ទទួលថាជួយ ទើបយកប្រាក់១០០បាទរាប់ឲ្យទៅដៃនាយ
ជា ហើយទារយកសំបុត្រដើមនោះ អំពីនាយជាៗក៏តែកោង
កុហកថា បាទទេកាលខ្ញុំបាទលោះចៅប្រាក់ពីម្ចាស់ដើមនោះ
ទើបបាន ៤ ៥ថ្ងៃពុំទាន់ធ្វើសំបុត្រទេ ថានឹងធ្វើហើយចៅប្រាក់
អង្វរខ្ញុំបាទថា ណាៗគង់តែនឹងចេញឆាប់ទេនឹងធ្វើសំបុត្របង
ថ្លៃសំបុត្រនោះថ្វី ហេតុនេះបានជាគ្មានសំបុត្រដើមនោះ អ្នក
កុំនឆ្កៀសចិត្តទៀយ មិនអីទេ យើងខ្ញុំនេះមិនអាចនឹងមកឆអ្នក
ផ្តេសផ្តាសឯណាបាន ស្រុកមានផ្ទះមានប្រមេទេអ្នកអ្នកកុំ
សង្ស័យទៀយ ចៅឡុកក៏ស្ងៀមពុំមានថាអ្វីទៀយប្រគល់
ប្រាក់ ១០០ បាទឲ្យទៅនាយជាៗ បានប្រាក់ក៏នៅចម្ងឹម្ងា ហើយ
លាចៅឡុចចុះមក ប្រើតែមុខសំឡក់ឲ្យចៅប្រាក់ ជាសញ្ញាថា
ព្រឹកស្អែកនេះសឹមចែកប្រាក់គ្នាឯផ្ទះអ្នកអ៊ូចុះ ហើយនាយជា
ដើរមកភូមិមាត់ស្ទឹងជាទីសំណាក់ខ្លួន នាយជាកើតលោភចេតនា
ប្រាថ្នាចង់បានប្រាក់នោះតែឯង ទើបកើតមិត្រទ្រុស្តដល់ចៅ

ប្រាក់ជាភ្ងៀនសំឡាញ់ គិតថាអញបានប្រាក់ហើយ គួរអញ
វិលទៅស្រុកជាឆាប់នឹងនៅដោយយឺយូរទៅ ក្រែងហេតុនោះ
នឹងកើតដល់ខ្លួន នាយជាគិតដូច្នោះហើយ ក៏ដើរទៅកាន់ផ្សារ
ស្វាយប៉ោ បួនប្រាក់បាទបានជាប្រាក់ទៀលធំចំនួនបាន១៦
ទៀលហើយក៏ទិញបាយចំណីបាវី ស្លា ជាសេ្បៀងតាមផ្លូវ ពេល
យប់នោះនាយជាក៏ចុះកប៉ាល់សាលុប ទៅទៀងកប៉ាល់ធំនៅ
ស្ទឹងបាក់ព្រាបាន វេលានាយជាទៅដល់ស្រុកឃ្លាំងសែ្បកចែក
ចាយប្រាក់នោះតាមអំពើពុតពាលទៅ ឯចៅឡុចនោះលុះព្រឹក
ទៀង និយាយនឹងចៅប្រាក់ថា ចាំពេលរួចបាយព្រឹកនេះ នឹងនាំ
គ្នាទៅធ្វើសំបុត្រឯសាសាក្នុងកំពែង ចៅប្រាក់នោះតាំងតែពី
នាយជាយកប្រាក់ថ្លៃខ្លួនអស់មក នៅមិនសុខទៀយចង់តែតាម
មកយកប្រាក់នោះអំពីដៃនាយជា ទើបនិយាយកុហកចៅឡុក
ថា អ្នកនឹងនាំខ្ញុំបាទទៅធ្វើសំបុត្រនោះ ទើឯប្រាក់ថ្លៃសំបុត្រ
នោះកុំចាំអ្នកចេញទៀយ ប្រាក់ខ្ញុំបាទមានហើយ តែខ្ញុំបាទផ្ញើ
ទុកនឹងបងខ្ញុំបាទ ឯភូមិមាត់ស្ទឹងឯនោះ ចាំខ្ញុំបាទទៅយកពីគាត់
សិន ទម្រាំបាយឆ្អែនខ្ញុំបាទបានមកដល់រួចបាយ សូមទៅធ្វើសំបុ
ត្រឯសាលាក្នុងកំពែងខ្ញុំសូមលាអ្នកទៅយកប្រាក់ពីបងសិន

ចៅឡុចក៏ជឿតាម បើកឲ្យចៅប្រាក់ទៅភូមិមាត់ស្ទឹង ចៅ
ប្រាក់បានឱកាស ក៏ខំដើរស្រូតត្រង់ទៅផ្ទះអ្នកអ៊ូ សួរនាកតួនាយ
ជាអ្នកអ៊ូក៏ប្រាប់ថា នាយជាបាត់ខ្លួនទៅតាំងពីថ្ងៃមុ្រិលមិញពុំ
ឃើញមកដេកដូចកាលពីមុនៗនោះទេ ចៅប្រាក់ធ្លាក់ចិត្តគិត
ថាអេះ អាជានេះបានប្រាក់ច្រើនហើយទំនងជាគេចនេះ មិន
ចង់ចែកអញទេដឹងចៅប្រាក់គិតហើយ តាំងដើរស៊ើបសួរដំណឹ
ងនាយជាតៗទៅ មានគេដឹងខ្លះគេក៏ប្រាប់ថា នាយជានោះ
ចំពោះជាចុះកប៉ាល់ទៅស្រុកវៀហើយ ចៅប្រាក់ឮថា នាយជា
ទៅស្រុកដូច្នោះ ក៏កើតទោមនស្សតូចចិត្ត គិតខេះខឹងនឹងនាយ
ជាជ្វាឃ្លាំងស្បែកក្រែពេកព្រោះពុំសមដូចសេចក្តីប្រាថ្នារបស់
ខ្លួន ម្ល៉ោះហើយចៅប្រាក់ក៏ដើរនេះពាត់គេចនេះ មិនឲ្យចៅ
ឡុចជានាយនោះឃើញទៀយ ឯចៅឡុចជាម្ចាស់ប្រាក់លុះដល់
ពេលបាយក៏ពុំឃើញរូបចៅប្រាក់មក ចៅឡុចកើតសេចក្តីក្តៅ
ក្រហាយ ក៏ដើរស៊ើបសួរនកពួកចៅប្រាក់នោះតែរាល់ថ្ងៃរាល់
ទៀលា កន្លងទិវាត្រីជាយូរថ្ងៃទៅ។ ថ្លែងឯក្មេងជាបាវលោក
សុភាទេស ដែលចៅប្រាក់ឲ្យឃ្លាលគោក្របីនៅជួស ជាដំណួស
ខ្លួននោះ លុះកន្លងយូរថ្ងៃមក ពុំឃើញចៅប្រាក់ទិលទៅវិញ

ដូច្នោះស្បៀងអាហារក៏អស់ទៅ ថ្ងៃ១នោះក្មេងដែលទទួល
បញ្ជើឃ្លាលក្របីនោះក៏ទៅផ្ទះ ដើមបីនឹងយកស្បៀងអាស្រ័យ
ទើបជំរាបលោកសុភាថា ចៅប្រាក់នោះវាប្រាប់ខ្ញុំថា មកស៊ី
ឈ្នួលគេបាន ២ ៣ថ្ងៃ ឲ្យខ្ញុំបាទនៅឃ្លាលក្របីចាំវា ឥឡូវនេះ
បាត់ខ្លួនចំនួន១៥ថ្ងៃនេះហើយ ពុំឃើញទិលទៅវិញទៀយ ពុំ
ដឹងជាទៅដំបន់ណាខ្ញុំបាទនៅឃ្លាលតែម្នាក់ឯងទេ លំបាកពេក
ណាស់លោកសុភាទេសឮថា ចៅប្រាក់នេះរត់បាត់ខ្លួនជាយូរ
ដូច្នោះហើយ ក៏ចាត់ប្រើអ្នកបំរើឲ្យដើរកតួចៅប្រាក់ អ្នក
បំរើដើរស៊ើបរកទៅក៏បានទៅជួបនឹងចៅប្រាក់នៅស្ទឹម
ចិន ទើបគេចាប់តួចៅប្រាក់មកជូនលោកសុភាទេស។ ក៏ឲ្យ
ដាក់ច្រវាក់លៀមចៅប្រាក់ប្រើឲ្យដំរះស្មៅ បោសសម្រាម
ផ្ទៃលមុខផ្ទះលោកសុភា។ ឯចៅឡុចដើរតាមរកតួតែសព្វៗ
ថ្ងៃលុះថ្ងៃ១ ចៅឡុកដើរទៅស៊ើបរកឯផ្សារស្វាយប៉ោលុះ
មកដល់ភូមិផ្ទះលោកសុភា បែរមើលទៅស្រាប់តែឃើញចៅ
ប្រាក់ ជាប់ច្រវាក់លៀមបោលសម្រាមនៅមុខផ្ទះលោកសុភា
ចៅឡុចក៏នឹកថា ចៅប្រាក់នេះមានទោសអ្វីអេះ បានជាលោក
ដាក់ច្រវាក់វានេះគិតហើយ ក៏ដើរចូលទៅរកលោកសុភា ដល់

ហើយក៏អង្គុយលុតជង្គង់សម្ពះ ដោយខ្លួនជាអ្នកតូចធ្លាប់តោខ្លាច
អ្នកធំ ដំរាបសួរថា "សូមមេត្តាអត់ទោសចុះចៅប្រាក់នេះកើត
ហេតុអ្វី បានជាព្រះតេជព្រះគុណដាក់ច្រវាក់វា? លោកសុភា
ប្រាប់ថា "ខ្ញុំអ្នកអើយខ្ញុំមិនចង់និយាយទេ អាប្រាក់នេះពេញជា
ខូចខិលណាស់ខ្ញុំឯងឲ្យទៅឃ្វាលក្របីឯវាលស្រែក្រៅ វាមិន
នៅឃ្វាលក្របីទេ្បីយ វាចេះតែដើរនេះពាត់ផ្តេសផ្តាសវេរ
ណាស់ ហេតុនេះបានជាខ្ញុំឯងឲ្យដាក់ច្រវាក់វានេះឯចៅទ្បូចឮ
ដូច្នោះហើយ ក៏ដឹងខ្សឹងជាចៅប្រាក់នេះវាជាខ្ញុំលោកសុភាពិត
ប្រាកដ ខ្លួនទៅលោះវានោះខុសច្បាស់ហើយ ចៅទ្បូចទាល់
ប្រាជ្ញាក៏អង្គុយស្ងៀមនៅ លោកសុភាក៏សួរថា ចុះអ្នកឯងត្រូវ
ការអ្វីបានជាមកសួរខ្សឹងអាប្រាក់នោះ" ។ ចៅទ្បូចក៏ដំរាប
តាមខ្សឹងខ្លួន មិនដឹងជាចៅប្រាក់ខ្ញុំគេខ្លួនបានលោះវាបង់ប្រាក់
១០០បាទ តាំងពីដើមដល់ចុង ដំរាបលោកសុភាសព្វប្រការលោក
សុភាក៏សើចហើយថា "មិនអីទេអ្នកទ្បូចខ្ញុំឯងបើកឲ្យ ចូរអ្នក
យកប្រាក់២០០បាទមកលោះយកវាទៅចុះ" ។ ចៅទ្បូចក៏ទាល់
គំនិតឆ្លើយថា "ខ្ញុំបាទជាអ្នកក្រ នឹងបានប្រាក់ពីណា២០០បាទ
នោះមកថែមលោះវាទៀត តែប្រាក់១០០បាទដែលបង់មុន

នោះគឺខ្ញុំតែខ្ញុំឯងផ្ទាំងឯងទេ" ។ លោកសុភាថា "បើដូច្នោះប្រាក់
ដែលបង់នោះមិនខូចទេហើយហ:នឹងចាំទារពីវានោះកាលណា
នឹងបាន ឲ្យអ្នកឯងចេញយកវាទៅចុះ សូមធ្វើសំបុត្រដាប់ជា
៣០០បាទទៅ ។ ចៅទ្បូចក៏ទាល់ទញ្ជឹចិត្តណាស់ អង្គុយគិតទៅ
ក៏យល់ការ ទើបសួរទៅចៅប្រាក់ថា "អើចៅប្រាក់ អាដែង
ដែលវានាំឯងទៅលក់នោះ តើឈ្មោះអីវានៅឯណាសព្វថ្ងៃនេះ!
ចៅប្រាក់ប្រាប់ថា "អានោះឈ្មោះអាជាជាតិជាជ្វា នៅស្រុក
បន្ទាយភ្នំពេញឥទ្បូវាត់ទៅស្រុកវាហើយ ប្រាក់នោះវាយក
ទាំងអស់ទៅពុំបានចែកខ្ញុំបាទទេ" ។ ចៅទ្បូចសួរសាំទៅទៀត
ថា" ចុះកាលវាមកនៅស្រុកយើងនេះ តើវាសំណាក់នៅផ្ទះអ្នក
ណាឯង? "បាទទាន វាសំណាក់នៅផ្ទះអ្នកអ៊ូនាងជា ភូមិផ្ទះនៅ
ក្រោមភូមិលោកមហាថៃ" ។ ចៅទ្បូចឮដូច្នោះហើយ ក៏លាលោ
កសុភា ចុះម្ដងម្នាទៅភូមិក្រោម សើបទីសំណាក់នាយជា នឹងមេ
ស្រុកភូមិនោះ បានដឹងច្បាស់ថា អ្នកអ៊ូជាមនុស្សគប់គឺតនឹង
មនុស្សអាក្រក់ យកមនុស្សអាក្រក់ឲ្យសំណាក់នៅផ្ទះ ចៅទ្បូច
ក៏ធ្វើខ្សឹងវាងវៃប្តឹងយកអ្នកអ៊ូ ហើយទៅប្តឹងឯសាលាក្នុងកំពែង ។
ឯចៅក្រមទទួលពាក្យបណ្តឹងនោះមើលដឹងសេចក្តីហើយ ក៏ឲ្យ

ទៅកោះយកនាយអ៊ូមកជំនុំជំនះពីភាកក្រតាមពាក្យចោទ។
អ្នកអ៊ូអាចឲ្យការកាត់បណ្តឹង ព្រោះចោអាងមេស្រុកជាបន្ទាល់
សំខាន់ ទាល់ប្រាជ្ញាក៏ទទួលសារភាពថាខ្លួនឲ្យសំណាក់គប់គឺតពិត
មែន។ ទើបចៅក្រមកាត់ក្តីនោះឲ្យអ្នកអ៊ូសងប្រាក់អ្នកដើម
ចោទជាប្រាក់១០០បាទ អ្នកអ៊ូសូមសន្យា៣ថ្ងៃនឹងយកប្រាក់
នោះមកបង់ ហើយទៅផ្ទះតាមទៀងខ្លួន លុះដល់កំណត់អ្នកអ៊ូ
យកប្រាក់១០០បាទទៅបង់សាលា ប្រគល់ឲ្យទៅដៃលួងស្រី
អញ្ជើតនោះ ជាអ្នកជក់អាភៀនពុំមានសេចក្តីអៀនខ្មាសយក
ប្រាក់នោះចាយ ទិញស្រាអាភៀនជក់ស៊ីទៅតាមអំណាចខ្លួន
ពាល។ លុះដល់ពេលល្ងាចចៅក្រមទៀងទៅចាំទទួលប្រាក់នោះ
តាមសញ្ញា ឯលួងស្រីអញ្ជើតឃើញចៅក្រមមកចាំយកក៏និយាយ
ថា ប្រាក់នោះនាយអ៊ូគេយកមកបង់ឲ្យហើយ តែខ្ញុំយកទៅទុក
ឯផ្ទះខ្ញុំឯនោះហើយ ឥឡូវនេះខ្ញុំឯងធុរៈនឹងការលោកម្ចាស់ទៀល
ពេកណាស់ នឹងទៅយកឲ្យអ្នកឯងពុំបានចាំថ្ងៃខានស្អែកចុះ សូម
មកយក ចៅក្រមក៏ទាល់សំដីនៅស្ងៀមទើបលាលួងស្រីអញ្ជើត
មកផ្ទះវិញ លុះកន្លងទៅបានពីថ្ងៃ ចៅក្រមទៀងទៅផ្ទះលួង
ស្រីអញ្ជើតៗនោះ ឃើញចៅក្រមមកដល់ផ្ទះខ្លួន ក៏វេះគេច

ពួនលាក់ខ្លួនពុំឲ្យជួបនឹងចៅក្រមៗ នៅចាំអស់ចិត្ត តាំងពីព្រឹក
ដល់ល្ងាចក៏ពុំជួប ចៅក្រមទឹងតែនំខានពេកណាស់ មិនបានក៏ទិល
ត្រឡប់ទៅផ្ទះវិញ។ លុះនៅយូរថ្ងៃទៅ ចៅក្រមក៏ឱសន្តាហ៍
ទៀងយកប្រាក់នោះទៀតក៏ពុំបាន ស្រីអញ្ជើតចេះតែនិយាយ
កុហកទៅផ្សេងៗ ចៅក្រមទារយកប្រាក់ពុំបានទឹងតែព្រួយ
ចិត្តខ្លាំង ទញ៉ាំគំនិតក៏គិតធ្វើវ៉ៃវ៉ាវក្លាយទោសលួងស្រីអញ្ជើត
នោះ ប្តឹងលោកកថាថនៗ លោកក៏ខឹងនឹងនាយស្រីអញ្ជើត
ព្រោះកោងឆវាស្ត្រ ទើបលោកឲ្យឃុំខាំងដាក់ទោសស្រីអញ្ជើ
តនោះ។ ឯចៅក្រមសោតក៏ពុំអាចប្តឹងទារយកប្រាក់នោះទៀ
តទៀយ ព្រោះស្រីអញ្ជើតនោះត្រូវវិក្តីហើយ ប្រាក់នោះក៏សាប
សូន្យអសាឥតការទៅហោង។ ទៀងពាលយ៉ាងនេះឯងស្តាប់
មើលចុះ ចៅក្រមខូចប្រាក់នោះព្រោះពុំមានសតិសម្បជញ្ញៈ
ត្រិះរិះឲ្យល្អិតល្អ ការដែលឆោតលុះអំណាចពាលនោះ ព្រោះ
តែសេចក្តីប្រាថ្នា ប្រារព្ធនូវវត្ថុទៀយៗ ទើបបង្កើតជាផ្លូវ
មនុស្សបាលទាដើរចូលបាន បុរាណលោកថា ឯសេចក្តីឃ្លានបាយ
១ ឃ្លានទ្រព្យ១ ឃ្លានស្រីឫទ្ធាញ៉ា១ ទាំង៣នេះជាវោគពាលតី
ជម្ងឺនេះមានដល់រូបណាហើយរូបនោះគង់នឹងឆោតមិនលែង

ហើយមនុស្សពាលទាំងបៀតបៀនមិនខានទៀយ ព្រោះ
សេចក្តីឃ្លានអ្នកស្រុកសន្ធឹកមកទៀយៗហើយ ដូចយ៉ាងចៅ
ពាលម្នាក់ទាំងទៅបៀតបៀនលោកសង្ឃ ឲ្យបង់ប្រាក់៥០រៀល
ឯងចាំស្តាប់មើលចុះ អញនឹងសំដែងប្រាប់ថាៈ

ទៀងលោកគ្រូចៅអធិការវត្តកោះ

កាលនោះមានបុរសម្នាក់ទាំងឯងថា លោកចៅអធិការវត្តកោះ
ស្រុកទន្លេធំលោកនោះបរិបូណ៌ដោយលាភសក្ការៈច្រើនចំរើន
ចិត្តប្រព្រឹត្តទៅក្នុងលោក បង្កើតសេចក្តីលោភទៀយៗៗ ថ្ងៃ
១បុរសពាលម្នាក់ទាំងស្លៀកពាក់ទៀបរយសុភាពរាបសា ប្រើអា
ការកិរិយាដូចជាឧបាសកអ្នករក្សាសីល ដែលមានសទ្ធាក្នុងព្រះ
ពុទ្ធសាសនា ចូលទៅរកលោកចៅអធិការៗ ក៏ធ្វើបដិសណ្ឋារៈ
ទទួលតាមសមគួរៗ ចៅពាលក៏និយាយថា ខ្ញុំកនុ្ណានឹងគិតធ្វើ
បុណ្យម្តាយក្នុងខែប្រាំងនេះឯត្រៀងទុយ្យទានគឺត្រៃចីវរ
ចំណែកខាងលោកទៀងខ្លានមាតិកានោះ ក៏បានជាវគែស្រេច
អស់ហើយត្រៃចីវរខាងលោកទេសនាសង្គាយនាត្រៃ៣ នោះក៏
បានចាត់ចែងស្រេចអស់ហើយ នៅតែត្រៃចំណែកអភិធម្ម
នោះ ពុំទាន់ធ្វើនៅទៀយព្រោះបងប្អូនកូន ប្រពន្ធខ្ញុំកនុ្ណាពី

គ្រោះយល់ព្រមគ្នាថា លោកទៀងព្រះអភិធម្មនោះគួរដល់ព្រះ
តេជព្រះគុណជាម្ចាស់នេះ ខ្ញុំកនុ្ណាមកនេះសូមអារាធនានិមន្ត
ព្រះតេជព្រះគុណទៀងព្រះអភិធម្ម នាំផ្លូវឲ្យមាតាខ្ញុំកនុ្ណាក្នុង
ការបុណ្យនោះឲ្យទាន ឯត្រៃសម្រាប់ប្រគេននោះ ចាំមកមើល
ត្រៃព្រៃរបស់ព្រះតេជព្រះគុណឯងនេះ ជាព្រះគុណសព្វព្រះហឫ
ទ័យព្រៃបែបណា ក៏នឹងទិញព្រៃខ្នាតនោះឲ្យត្រូវព្រះហឫទ័យ
សូមទានព្រៃត្រៃគំរូមើលនឹងបានចាត់ចែងតាម ឯលោកចៅ
អធិការឮចៅពាលពោលត្រូវចិត្តដូច្នោះហើយ ក៏តបថាចំនើន
ពរ ត្រៃព្រៃអាត្មាភាពមានខ្លះដែរ តែមិនសូវត្រូវចិត្តអាត្មាប៉ុ
ន្មានទេ បើឧបាសកមានសទ្ធាយ៉ាងនេះមានតែទៅមើលត្រៃឯ
ផ្ទះនត្រៃយម្ខាង ព្រៃយ៉ាងណាក៏មានសូមទានបើដូច្នោះ និមន្ត
ព្រះតេជព្រះគុណជូនខ្ញុំព្រះកនុ្ណាទៅមើល បើត្រូវព្រះហឫ
ទ័យព្រៃបែបណា ខ្ញុំព្រះកនុ្ណានឹងជាវបែបនោះមកធ្វើព្រគែ
នចំនើពរ បានមិនអីទេថាហើយចៅអធិការហៅប្រើកូនសិស្ស
ឲ្យទៅទៀបទូកក្តារ ឯក្មេងកូនសិស្សក៏នាំគ្នាទៀបទូកបញ្ចុះ
លោកគ្រូនឹងចៅពាលនោះចែវឆ្ពោះត្រង់ទៅដល់ត្រៃយម្ខាង
ទំនងយ៉ាងផ្ទះស្រុកនការកោងទើបចាត់ឲ្យអ្នកចែវនៅចាំទូក

លោកចៅអធិការក៏នាំចៅពាលនឹងក្មេងស្តាយយាមទៀងទៅ
ផ្ទះ ដើរទៅដល់ផ្ទះចិនៗ ក៏និមន្តឲ្យចូលទៅចិនឃើញលោក
គ្រូធំមកផ្ទះខ្លួន ក៏ត្រេកអរនឹងទៀបអាសនានិមន្តលោកឲ្យគង់
ហើយសួរថា លោកគ្រូម្ចាស់និមន្តមកដោយត្រូវការអ្វី?។

ចំនែនពរអាត្មាភាពជូនឧបាសកនេះមកទិញព្រៃធ្វើត្រែ
ព្រៃសៀងហៃយ៉ាងល្អនោះ តែជាមានខ្លះដែរឬអ្នកដង្ហៅ។

កន្ទុំណាម្ចាស់មានខ្លះដែរលោកគ្រូម្ចាស់ត្រូវការខ្ញុំកន្ទុំណានឹង
យកមកប្រគេនទុតមើល។ ចំនែនបពរយកមកមើលអ្នកដង្ហៅ។
ចិនក៏នែនព្រៃច្រែនក៏ស្រាយលាតឲ្យលោកគ្រូនឹងចៅពាលនោះ
មើល លុះនែសមើលទៅបានព្រៃល្អ២ភី លោកចៅអធិការក៏
និយាយទៅកាន់ចៅពាលនោះថា ព្រៃ២ភីនេះត្រូវចិត្តអាត្មាហើ
យបើអ្នកត្រូវការនឹងសាងត្រែ គប្បីយកព្រៃខ្នាតនេះចុះ។

ចៅពាលក៏តបថា កន្ទុំណាម្ចាស់បើព្រះតេជព្រគុណសព្វព្រះហ
ឫទ័យហើយ ខ្ញុំកន្ទុំណានឹងជាទិចុះថ្លៃថ្នូរប៉ុន្មានអ្នកដង្ហៅ។ ចិនក៏
កាត់ថ្លៃ៥០ទៀលជាការដាច់ខាត ចៅពាលក៏ថាបានខ្ញុំបានយក
ហើយធ្វើម្តេចឯងប្រាទព្វធ្វើបុណ្យ ចំពោះព្រះតេជព្រះគុណ
ហើយ ថ្លៃយ៉ាងណាក៏ចេះតែយក តែប្រាក់ខ្ញុំជាប់មកនេះតែ២០

ទៀលទេ មិនគ្រប់គ្រាន់បើដូច្នេះសូមនិមន្តព្រះគុណនៅគង់ទន់
ចាំខ្ញុំព្រះកន្ទុំណានឹងទៅយកប្រាក់អំពីបងនៅភូមិលើមកបង្គ្រប់
លោកចៅអធិការក៏ថាចំនែនពរ អញ្ជើញទៅឲ្យឆាប់ចុះអាត្ម
នៅទន់ចាំនៅនេះ ឯចៅពាលក៏លាលោកនឹងចិនចេញទៅភូមិ
លើ ដើរអមទៅកំពង់ដែលចតទូក ហើយប្រាក់កូនសិស្សដែល
ចែនទូកមកនោះថា ឥឡូវនៃព្រះគុណប្រើឲ្យយើងនាំចៅ
ឯងទៅយកប្រាក់៥០ទៀលឯកុដិលោក ឯពួកកូនសិស្សទាំង
នោះក៏ជឿតាម ទើបចុះចែនទូកឆ្លងមកដល់ទត្តកោះហើយ ក៏
ទៀងទៅប្រាប់លោកសង្ឃដែលនកុដិកាន់កូនសោនោះថា
ព្រះតេជព្រះគុណប្រើឲ្យមកយកប្រាក់៥០ទៀល ទៅឲ្យថ្លៃ
ទំនិញចិន ឯលោកសង្ឃនកុដិក៏ជឿ ទើបចាក់សោហិបបើក
យកប្រាក់៥០ទៀលប្រគល់ឲ្យទៅដៃចៅពាលៗ ក៏នាំកូន
សិស្សចុះចែនទូកឆ្លងទិលទៅត្រើយទិញ លុះដល់ហើយចៅ
ពាលថា ចៅឯងទាំងអស់គ្នានៅចាំទូកចុះ ខ្ញុំឯងនឹងយកប្រាក់
នេះទៅប្រគេនលោកគ្រូ ថាហើយក៏ទៀងម្ចាស់ចេញទៅទិស
បូព៌ មានមុខឆ្ពោះត្រង់ចូលព្រៃយកប្រាក់នោះទៅកែខែបវ
ភោគតាមប្រាថ្នា។

ថ្លែងឯលោកចៅអធិការនៅវង់ចាំចៅពាលតាំងតែពីពេលថ្ងៃត្រង់ លុះដល់ពេលល្ងាចចិនក៏បំរុងទឹកតែស្កុនសអស់ ៣ ៤ បាន់ក៏ពុំឃើញចៅពាលនោះមក ម្ល៉ោះហើយទំខានព្រះហឫទ័យខ្លាំង ក៏ឲ្យចិននោះយកព្រៃទៅទុក ចំទើបពនលាចិនចុះមកកាន់កំពង់ទឹកហៅសិស្សឲ្យចែវទូកឆ្លងវិលទៅវត្តកោះ តាំងពោលជេនចៅពាលនោះថា អាឧបាសកចង្រៃឲ្យឯងជូនមកទិញព្រៃធ្វើត្រែ តថ្លៃចិនស្រេចហើយវានេះទៅឯណាបាត់ ឲ្យឯងលំបាកចាំផ្លូវនាអស់១ថ្ងៃទទេទៅ ឯកូនសិស្សអ្នកចែវទូកឮលោកគ្រូពោលដូច្នោះ ក៏ទូលថាឧបាសកនោះ គាត់មកឲ្យពួកយើងខ្ញុំនេះចែវទូកបញ្ជិះគាត់ឆ្លងទៅយកប្រាក់៥០ទៀល អំពីលោកបងដែលចាំកុដិ គាត់ថាព្រះតេជព្រះគុណប្រើឲ្យទៅយកប្រាក់នោះបានហើយ គាត់ក៏ទៀងពីកំពង់ទៅ ថាយកប្រាក់ទៅប្រគេនព្រះតេជព្រះគុណឯជ្រាន ព្រះកទុណាមិនឃើញគាត់ទៅដល់ ព្រះតេជព្រះគុណទេឬ លោកចៅអធិការថា ឱអីចុះអាអញ្ជើមានប្រើឲ្យវាទៅយកប្រាក់កាលណា វាលាអញ្ជើមកថាវាទៅយកប្រាក់អំពីបងប្អូនវា ឯភូមិលើទេ នេះវាប្រែថាអញ្ជើប្រើវាមកយកប្រាក់ឯកុដិអញ្ជើវិញ អើបើដូច្នោះវាអស់ហើយ

ប្រាក់អញ្ជើនោះ អាឯងទាំងអស់គ្នាមិនគួរទៅជឿវា ខំចែវទូកពីនបីត្រឡប់ប្រាក់ក៏បង់ថង់ក៏ដាចហើយពួកអ្នកចែវទូក នឹងមិនជឿវាឯណាបានព្រោះវាទៀងទៅជាមួយនឹងព្រះតេជព្រះគុណលោកចៅអធិការក៏ទាល់សំដីនឹងពួកកូនសិស្ស ថាអើបើដូច្នោះខំចែវទៅឲ្យឆាប់ តរួតពេលជិតយប់ហើយក្រែងត្រូវទឹកខ្យល់ព្យុះខ្លាំង ផាត់មកលិចទូកក្តារណាអា អ្នកចែវក៏គ្នាខំចែវទូក ត្រាតែដល់កំពង់វត្ត ល្មមពេលម៉ោង៨ ៩យប់ លោកចៅអធិការទៅដល់កុដិហើយ ក៏ទឹតតែកើតទោសោបន្ទោសទៅលោកដែលនៅចាំកុដិថា មិនគួរទៅជឿមនុស្សនឹងដល់ចាក់សោយកប្រាក់ឲ្យទៅ អាមនុស្សពាលនោះសោះលោកដែលនៅចាំកុដិឆ្លើយថា មិនជឿឯណាបានព្រោះក្មេងចែវទូកវាមកផង លោកគ្រូក៏ទញ្ជាទាល់នៅៗនោះទៀត មានសេចក្តីពុំសប្បាយ ដោយចាញ់កលមនុស្សដោយប្រការយ៉ាងនេះ ។

ចប់រឿងលោកគ្រូវត្តកោះអស់សេចក្តីត្រឹមនេះ។

ពាក្យក្មេងវាច្រៀង សង្ឃអើយលោកសង្ឃ តែមានចំណង់តងបង់បច្ច័យ លោកគ្រូវត្តកោះ ព្រោះត្រេកនឹងត្រែ អាពាលចង្រៃ ទើបានហាសិប ។

ទៀងពាលនេះមានឧបាយកលបញ្ឆោតច្រែនប្រការណាស់ ឯស្តាប់មើលចុះតែពុំមានប្រាជ្ញាត្រិះទិះតាមអាការទាចេញនោះហើយ ក៏គង់ធ្លាក់ចុះក្នុងកលទាដូចពណ៌នាមកនេះឯង ។

មានមនុស្សពាល១ទៀតទាប្រើឧបាយតែពីចម្ងាយឆ្ពុះមកឲ្យមនុស្សជឿបាន ដូចនិទានលោកចៅអធិការមួយអង្គ គង់នៅវត្តស្រុកខាងលើជ្រោយចង្វានេះឯងទៅចុះជឿមនុស្សពាលឲ្យខូចប្រាក់៨០ ទៀលនិទាននោះថា កាលនោះលោកចៅអធិការមានភ័ព្វប្រោនឲ្យនឹងធ្វើព្រះវិហារ បានឃោសនាឧបាសក ឧបាសិកាដើងវត្តបានប្រាក់៨០ ទៀលអាចវ្យវត្តចាត់ទុកនៅដៃលោកចៅអធិការ ប្រាថ្នានឹងទិញឈើធ្វើព្រះវិហារ ។

ទៀងលោកសង្ឃសាងវិហារ

ថ្ងៃ១ មានបុរសពាលម្នាក់ទាដឹងថា លោកគ្រូនោះមានប្រាក់៨០ទៀល ទើបទាតែកាយស្លៀកពាក់ហាក់ដូចជាដង្កៀឈើ មានចៅពាលម្នាក់ទៀត ធ្វើជាកូនឈ្លួលដើរតាមក្រោយ ចូលទៅវត្តនោះដល់ហើយទាទៀងទៅឯទីវិហារចាស់ ធ្វើកិរិយាពុំនាំពាក្យចរចានឹងអ្នកណា១ទៀយទាឲ្យកូនឈ្លួលនោះទាញខែ្សម្ខាង ទាទាញម្ខាងទាទាស់ទទឹងបណ្តោយវិហារហើយទាធ្វើ

ជាសរសេរខ្នាតដាក់សៀវភៅ ទាស់ព្រះវិហារនោះទៅមកតែពីរនាក់នឹងកូនឈ្លួល ។ ឯបណ្តាភិក្ខុសាមណេរទាំងឡាយឃើញអាពីរនាក់ទាញខ្នាតទាស់ព្រះវិហារខ្លួនដូច្នោះ ក៏សង្ស័យទីទៃ ។ លោកខ្លះទៅពិតទូលលោកចៅអធិការ ។ ក៏នឹងសង្ស័យថា ឧបាសកគេមកទាស់វិហារយើងនេះហេតុអ្វីអេះ! ទំនងគេនឹងចង់ជួយសាងវិហារយើងដឹង បើដូច្នេះគួរតែទៅស៊ើបសួរមើលឲ្យដឹងការ ថាហើយលោកចៅអធិការទៀបអាត្មាសុភាពដើរទៅរកចៅពាលនោះ ឯចៅពាលយល់លោកគ្រូចៅអធិការមកដល់ ក៏ធ្វើជាឈប់ទាស់តាំងសរសេរកត់ដាក់សៀវភៅហើយបែរទៅលើកដៃសម្ពះថា លោកម្ចាស់នេះឬជាចៅអធិការវត្តនេះ? ចំទើនពរ អាត្មាភាពនេះឯងជាចៅអធិការ កន្ទុណាម្ចាស់ព្រះវិហារនេះ ជាមានលោកអ្នកឯណាគិតធ្វើហើយឬពុំមានទេ? ចំទើនពរ ពុំមានលោកអ្នកឯណាមានសទ្ធាធ្វើទេ តែរូបអាត្មាភាពនេះ ឃោសនាញាតិញោមដើងវត្តបានបច្ច័យបន្តិចបន្តួច នឹងធ្វើពុំទាន់បានចំទើបពរ ឱបើដូច្នោះកន្ទុណាម្ចាស់ប្រោសមេត្តាខ្ញុំកន្ទុណាសាងទៅដឹងវិហារនេះ ព្រោះខ្ញុំព្រះកន្ទុណាជាដង្កៀឈើបាននាំមកហើយ តែពុំទាន់ដល់ទីនេះនៅ

ទៅវិញខ្ញុំព្រះកនុ្ណាចុះមកមើលទី នឹងដាក់ក្បួនឈើជាមុនសិន្សៀ
ឃើញទីកំពង់ទំនេរលោកគ្រូម្ចាស់នេះទីទូលាយសប្បាយ គួនដាក
ចំណាយបានមួយទៀតទើងឈើធ្វើវិហារនោះ ខ្ញុំព្រះកនុ្ណា
បានចាត់មកនឹងក្បួនជាស្រេច បើខ្វះខាតទៀត សូមលែលក
យកឈើក្បួននោះថែមថយ ត្រាតែឲ្យគ្រប់កនុ្ណាម្ចាស់កុំព្រួយ
ព្រះទ័យទៅវិញ សូមតែកំឡាំងជួយលើកជួយដាក់សែងលី
ប៉ុណ្ណោះចុះ តែខ្ញុំព្រះកនុ្ណាតិចគ្នានឹងធ្វើ។ "ចំនើនពរ បានទេ
ឯខាងកំឡាំងសែងលីនោះ ជាភារៈលើអាត្មាភាពចុះ"។ "កនុ្ណា
ម្ចាស់បើលោកគ្រូម្ចាស់ជួយផងនោះ ការនោះយល់ជាតើតឆាប់
"។ ចៅពាលនិយាយប្រៀបប្រាយបណ្តើរ ធ្វើជាប្រើអាការ:
បន្តិចបើកនាលិកាដាក់មើលម៉ាង បន្តិចធ្វើជាទើយកក្រដាស
ប្រាក់អំពីថង់សែ្បកមកនាប់ លោកចៅអធិការឃើញចៅពាល
ទាំសំដែងចេញដូច្នោះក៏ទឹតតែជឿពេញចិត្ត ហើយថាចំនើនពរ
អញ្ជើញញ្ជោមដង្ហៅទៅឯកុដិសិន។ កនុ្ណាមិនអើទេ។ថា
ហើយក៏នាំកូនឈ្លូសទៅឯកុដិលោកចៅអធិការ។ ឲ្យក្មេងយក
កន្ទេលថ្មីខ្ចីយថ្ម ទៀបទទួលហើយអញ្ជើញចៅពាលឲ្យអង្គុយ
សមគួនហើយ ឲ្យក្មេងសិស្សដាំតែល្អស្តុនល្អតាងលៀងចៅពាល

នោះ ឯចៅពាលក៏សន្ទនាប្រប្រស័យនិយាយពីទៀងធ្វើវិហាន
នោះជាអនេកបទិយាយផ្ទេរងៗ។ លោកចៅអធិការក៏ទួល
នាយសប្បាយចិត្ត ព្រោះតួតែត្រូវទំអានម្មណ៏ដែលសន្សំមកយូរ
ហើយលុះពេលល្ងាច ចៅពាលក៏ថ្វាយបង្គំលាចុះម្ចីម្ចាដើរចេញ
មកបន្តិច ក៏គេចចូលទៅទិញ្ញហើយថា "កនុ្ណាម្ចាស់ឥទ្ធិនេះ
កូនឈ្លូលទាសូមបើកប្រាក់ខ្ញុំកនុ្ណាមានតែក្រដាស់ប្រាក់១០០
នឹងចែកចាយពុំបាន សូមទានប្រាក់ដែលឃោសនានោះ សូមខ្ចី
ចាយសិន ទំរាំតែខ្ញុំព្រះកនុ្ណាទៅប្តូរពីផ្ទះរបាន ឬលោកគ្រូ
ម្ចាស់មិនជឿចិត្ត ក៏សូមនិមន្តយកប្រាក់ក្រដាស់១០០ នបស់ខ្ញុំ
កនុ្ណាទុកជាសំខាន់ចុះ"។ ឯលោកចៅអធិការនោះ លុះអំណាច
ជឿជដាប់ហើយ ទើបឆ្លើយថា "ចំនើនពរបានទេ"។ ថាហើយ
ក៏ចូលទៅក្នុងកុដិចាក់សោរហិបបើកយកប្រាក់៨០ទៀលចេញ
មកឲ្យទៅដៃចៅពាល។ ក៏ទទួលមួយរំពេចទៀចដាក់ក្នុងថង់
សែ្បកហើយថា "កនុ្ណាម្ចាស់យកប្រាក់ក្រដាស១០០នបស់ខ្ញុំ
ព្រះកនុ្ណាទុកជាដំណាងឬដូចម្តេច"។ "ចំនើនពរមិនអើទេ
អញ្ជើញយកទៅចុះ ទុកនៅលើញ្ចើមដង្ហៅក៏ដូចជាទុកនៅ
លើអាត្មាភាពដដែល ការវិហារសីមានោះ ក៏ស្រេចនៅលើ

ញ្ជោមដង្ហៅហើយ អញ្ជើញទៅហើយសូមមកទីញុំយូរពេក"។

ចៅពាលបានឱកាសហើយក៏ម្ចឹងចេញទៅខាងផ្លូវទីមាត់ទន្លេដើរទៅកាន់ភូមិក្រោម ត្រដរល់ភូមិជ្រោយចង្វា ចៅពាលនាំគ្នាចុះនាវា (គឺទូកដ) ឆ្លងដរលើត្រើយក្រុងភ្នំពេញ តាំងទីញ្ជ្រាបាយចំណីឬអាភៀនញៀន ដល់ចូលទៅងនាងកិន្នរីស្រីផ្កាមាសដោយអំពើពាលហោង។ ឯលោកចៅអធិការនោះនៅទន់ចាំមើលកូនឈើជាយូរថ្ងៃ ក៏ពុំឃើញមានធ្លាក់មកដល់១ទៀយ ម្ល៉ោះហើយទឹងជាទុក្ខទោមនស្សនៅ លុះកន្លងខែ១២ទៅ ក៏តែតទីប្បដិសាវី រំលឹកឃើញសេចក្តីដែលខ្លួនឆោតខ្លៅឲ្យអាពាលដង្ហៅខ្ចីប្រាក់៨០ ទៅស៊ីបាត់ម្តង ទាំងពួកញ្ជ្រៅតញ្ជ្រមផង ក៏នាំគ្នាតែកងស្តីបន្ទោសលោកចៅអធិការថា "លោកឥតប្រាជ្ញាស្មានតែ ទៅជឿមនុស្សពាលអប្រិយឲ្យទាបញ្ជូតយកប្រាក់អស់ ខានសាងព្រះវិហារ"។ ខ្លះក៏អស់សង្ឃា លែងចេញប្រាក់ចូលឃោសនាទៀតលោកចៅអធិការ ក៏ទឹងជាទុក្ខសល់សែនណែនឱនាព្រោះពុំសមក្តីប្រាថ្នា ដោយប្រការយ៉ាងនេះហោង។

ចប់រឿងសង់ព្រះវិហារ។

ពាក្យក្មេងទាច្រៀងថា ពាលអើយចៅពាល ចេះទាសទីហានឲ្យសង្ឃសង្រ្គយ សង្ឃសាងទីហាន មានមានចង្រៃ កន្លងទីស័យបង់ប៉ែតសិបទៀល។

អើទៀងពាលនេះ ឯងស្តាប់មើលចុះសុទ្ធសឹងមានឱបាយកលផ្សេងៗ ធ្វើឲ្យអ្នកស្រុកទាំងលោកសង្ឃនូវនឱបាសកឲ្យលុះអំណោចទា បាននូវសេចក្តីក្តៅក្រហាយដូចបាននិយាយមកនេះ ហេតុនោះទើបថាមនុស្សពាលនេះ គួរខ្លាចណាស់ពាលនេះ មានពុតអំពើធ្វើពុំតែមឺងទេ សឹងមានច្រើនយ៉ាងណាស់ពុំឃ្លះនឹងពណ៌នា មានពាលខ្លះប្រើមានយោទយ៉ាងស្ងួទ្ធ ពាលខ្លះប្រើអំណោកាច់កិនសង្កត់កំហែង លក់ព្នៃអ្នកស្រុក ដោយអាងខ្លួនថាជាញ្ជ្រាតនឹងអ្នកធំ។

ទៀងឱកញ្ជ្រោញញៀនអាភៀន

មានចៅពាលម្នាក់ទីជាឱកញ្ជ្រោ ជាព្រះញ្ជ្រាតនឹងសម្តេចព្រះបរមខត្តិយា ឱកញ្ជ្រោនោះដក់អាភៀនញៀនពេញកំឡាំងតែអស់ប្រាក់កាលណា ទាក៏នាំបណ្តាកូនក្មួយបាវព្រាវ ចុះទូកតែហ៊ែបែចទ្រាច់ទៅតាមទន្លេធំដល់ភូមិណា ស្រុកណាហើយទាឲ្យអាបាវព្រាវនោះទៀងកាប់ចេកកាប់អំពៅ បេះផ្លែឈើ តឹផ្លែ

ត្រសក់ ឱ្យវ៉ែក ដៃញ្ចាប់មាន់ទាបស់នាស្តុយកជាប្រយោជន៍
ខ្លួនវា ថ្ងៃ១នោះ ចៅខុកញ្ជ្រោឲ្យបាវចែវទូកទៅចតទៀប
កំពង់ភូមិស្រុកនកាទ្វារ អាបាវវានាំគ្នាទៅដល់ទៅកាប់ចេកនបស់
តាក្រែសនញ្ជឹមៗពុំបាននៅៗ តែយាយជាប្រពន្ធ អស់ពួកនោះ
វាតស្ទាត់កាប់ចេកជាង១០ស្មង ហើយវានាំគ្នាសែងលើមកដាក់
ទូក នៅសល់ចេក១ស្មងពុំយក ព្រោះចេកនេះនៅខ្ចីណាស់ គឺត
ហើយយាយនោះ លើកយកចេកនោះដាក់ទៅលើវានហាល ។

ដល់ក្រោយ អាបាវម្នាក់វាដើរចូលទៅបានឃើញចេកដែល
កាប់នៅលើវានហាលយាយ ទើបវាក្តែងថា "យាយឯងនេះម្តេច
ហ៊ានលួចចេកលោកនាយយើងទៅប្តឹងលោកនាយឲ្យដឹះចោរ
លួចចេកនេះហើយ" ។ យាយម្ចាស់ចេកឆ្លើយថា ឱកូនអើយ!
ម្តាយនេះលួចចេកកូនឯងកាលណា ម្តាយស្មានថាចេកនេះវាខ្ចី
ពេកស្មានឯងកាប់មកក្រែងច្រឡំថាចាស់មិនយកទៅ ចោល
នៅក្នុងទីនេះយ៉ាងជាកូនមិនត្រូវការដឹង បានជាម្តាយលើកដាក់
មកលើវានហាលនេះ ឥឡូវបើកូនត្រូវការហើយ ក៏អញ្ជើញ
ទៅចុះម្តាយនឹងថាអី ។ អានេះមិនស្តាប់វាទៅប្តឹងខុកញ្ជ្រោនាយវា
ឯនាយនោះនឹងបាវវាដឹងគ្នា ទើបឲ្យពួកវាទៅដើរទៅកោះ យក

យាយនោះមក យាយនោះភិតភ័យក្រែពេក ដល់ហើយវាកាត់
លក់យាយនោះជាប្រាក់៣ណែន យាយនោះសូមអង្វរទៅត្រឹម
១ណែន ១កំណាត់ យាយម្ចាស់ចេកក៏បង់ចេក១០ស្មង នឹងប្រាក់
១ណែន ១កំណាត់ ទៅដែខុកញ្ជ្រោបាលនោះឯង ។

ឯងស្តាប់មើលទៅចុះស្រុកខ្មែរយើងនេះ ពីដើមមានមន្ត្រី
ពាលដើរបៀតបៀនរាស្ត្រ ឲ្យរាស្ត្រក្តៅក្រាយផ្សេងៗ ដូច
យ៉ាងខុកញ្ជ្រោពាលដែលវាកំហែងយាយម្ចាស់ចេកនៅស្រុកនកា
ទ្វារជាប់គ្នានឹងស្រុកព្រែកពោធ៍នោះឯងទាល់តែរាស្ត្រស្រុក
ទន្លេធំ ទរអាខ្លាចអំណាចខុកញ្ជ្រោពាលនោះ តែឃើញទូកតែ
ហ៊ៅចៅខុកញ្ជ្រោពាលនោះចតនៅកំពង់ភូមិណាហើយ ក៏មិនហ៊ា
ននិយាយថាអ្វីទៀយ ទោះជាពួកនោះកំហែងកាប់ចេក កាប់អំ
ពៅឬដៃញ្ចាប់មាន់ទាក្តី ក៏ពុំហ៊ានហាមឃាត់ថាអ្វីទៀយ ។

ឯអំពីចៅខុកញ្ជ្រោពាលកំហែងលក់រាស្ត្រនោះមិនតែ
ប៉ុណ្ណោះទេ សឹងមានច្រើនប្រការទៅទៀត យើងសំដែងតែជា
និយសង្ខេបប៉ុណ្ណោះ ឲ្យឃើញថាពាលនេះវាប្រើខុបាយកល
កោងបញ្ឆោកុហកបោកប្រាសខ្លះ វាប្រើកំហែងលក់ព្នៃដោយ
អំណាចវា ដែលវាជាមន្ត្រីអាងខ្លួនជាធំ ជាព្រះញ្ជាតិវង្សពង្ស

និងមហាកប្បត្រខ្លះ ហេតុនោះទើបថាខ្លាចអ្វីមិនស្មើខ្លាចពាល
កាចអ្វីមិនស្មើកាចមនុស្សពាល មនុស្សមានអំណាចនឹងគិតបៀត
បៀនបុគ្គលណាហើយ ទោះមនុស្សនោះមានប្រាជ្ញាឆ្លាស់យ៉ាង
ណា នឹងគិតកែឲ្យផុតពីមនុស្សពាល ដែលមានអំណាចនោះ
គេចទៅពុំបាន ព្រោះមនុស្សពាលយកយសសក្តាជាអំណាចមក
គ្របសង្កត់បំបាត់មាត់អ្នកតូច មិនឲ្យហើបហាថាអ្វីបានដូចបុរា
ណថា "ពាលប្រើអំណាចប្រាជ្ញតោងប្រាសចេញ"។

មួយទៀតថា ជាតិអ្នកតូចទោះមានប្រាជ្ញាចេះគេចកែក៏
គេចកែបានក្នុងវារៈ ១២ ដងតែបើពាលព្យាយាមមនឹងយាយី
ហើយ គេចទៅទៀតពុំរួចទៀយដូចនិទានកូនចៀមត្រូវឆ្កែ
ព្រៃវាកំហែងចាប់ស៊ីនោះឯង។

រឿងកូនចៀមនឹងឆ្កែព្រៃ

មានកូនចៀម១ចុះទៅផឹកទឹកជ្រោះ កាលនោះមានឆ្កែព្រៃ
១ចុះទៅផង បានឃើញកូនចៀមនោះហើយ កើតកួចចង់
ចាប់ស៊ី តែឆ្កែនោះគិតថាការនឹងកំហែងចាប់ស៊ីតែម្តងទៅក៏
បាន ប៉ុន្តែហាក់ដូចជាមិនអស្ចារ្យចាំរកទោសវាឲ្យឃើញសិន
គិតហើយឆ្កែព្រៃស្រដីកំហែងទៅថា ទ្រុយអាកូនសត្វនេះម្តេច

ឯងក៏ខូចខិលម្ល៉ះ គួរឬមកកូរទឹកឲ្យល្អក់អស់ រកតែយើងនឹងផឹកផងពុំបានហះ។
ឯកូនចៀមឮឆ្កែព្រៃពោលចាប់ទោសដូច្នោះ ក៏តបថាខ្ញុំបានទទួលទានទឹកនៅក្រោមលោកទេតើ ទឹកល្អក់ឯណាដែលហូរច្រាសទៅខាងលើនិញ្ញនោះលោកនៅខាងលើខ្ញុំបាទយ៉ាងនេះ។
ឆ្កែព្រៃទាល់ប្រាជ្ញា ទើបរកកលចាប់ទោសឯទៀតនិញ្ញថែងចោទថា "អើពីឆ្នាំទៅមិញឯងដើរនិយាយដើមអញៗតែរកទេតើ"។ "បាទលោកបើគិតទៅរូបខ្ញុំបាននេះ មិនទាន់ទាំងកើតផងបើជាកើតសោតក៏នៅពុំទាន់ចេះនិយាយផង ហេតុម្តេចលោកមកចោទខ្ញុំបានថា ដើរនិយាយដើមលោកពីឆ្នាំទៅមិញ្ញនោះ"។ ឆ្កែព្រៃទាល់ប្រាជ្ញារកកលមួយទៀតកំហែងទៅថា "អើបើអាឯងមិននិយាយព្រោះនៅតូចទន់ បើដូច្នោះគឺបងអាឯងនិយាយដើមអញ"។ "ខ្លួនខ្ញុំបាទនេះ កើតជាកូនដំបូងក្នុងឱទរនៃមេខ្ញុំបាទនេះ បងខ្ញុំបាទនឹងមានកាលណាគឺខ្ញុំបាទនេះហើយជាកូនច្បង ហេតុម្តេចលោកមកចោទខ្ញុំបាទថា បងខ្ញុំបាននិយាយដើមលោកដូច្នេះ"។

"ឱបងអាឯងគ្មានសោះហះ បើដូច្នោះម៉ែឱ្យដីដូនតាអាឯង

និយាយដើមអញ្ជើហើយ"។

កូនចៀមឮឆ្កែព្រៃចោទសេចក្តីតោងមិនដល់នឹងគេចកែមិនដល់ដូច្នោះ ក៏ពុំអាចឆ្លើយតបបាន ទើបឈប់ស្ងៀមនៅឆ្កែព្រៃក៏ស្ទុះទៅចាប់កូនចៀមនោះប្រហារបរិភោគក្នុងកាលនោះឯង។

ពាក្យឆ្កែព្រៃចោទចាប់ទោសដល់ម៉ែ៎ ដីដូនដីតានេះជាពាក្យធ្ងន់លើសប្រមាណទោះប្រាជ្ញាពោធិសត្វគង់គេចកែទៅមិនផុត នរណាទៀតក្នុងលោកនេះដែលគ្មានមាតាបិតាដីដូនដីតានោះ សឹងមានគ្រប់រូបទាំងអស់ច្បាប់បញ្ញត្តថា នរណាមានទុសទណ្ឌកម្មហើយត្រូវទៅច្បាប់ស៊ីដល់កូនចៅដែលកើតក្រោយផងដូចច្បាប់ក្នុងស្រុកលើ គេបញ្ញត្តថាបើមានអ្នកណាចេះធ្លាប់ចេះអំពីព្រោយ ហើយមានគេទៅប្តឹងដល់មេកន្ត្រាញ ជាមេស្រុកនោះមេកន្ត្រាញត្រូវទៅមានអំណាច ឲ្យទៅកោះចាប់យកអ្នកដែលគេចោទនោះមកជំនះពីភាក្យា បើជំនះទៅយល់មែនដូចពាក្យគេចោទហើយ ច្បាប់ត្រូវទៅសម្លាប់ពូជនោះអស់៧សន្ថាន ដោយហោចទៅតែទារកបៅដោះក៏ឲ្យសម្លាប់ទាំងអស់។

មួយទៀតបើនរណាពួកណាប្រទូស្តគឺកូវត់ដែនដីក្តីប្តឹ ទទឹងទឹងទូសតអាជ្ញាមហាកប្រត្តិ ច្បាប់ត្រូវប្រហារជីវិតទាំងត្រកូលឯពួកញ្ញាតិពូជនោះ ត្រូវទំលាក់ដាក់ជាពលអ្នកជាន មានឲ្យត្រូវបោចស្មៅសេះស្មៅដំរីជាដើម ត្រាអស់កប្បអស់កល្បទៅ សត្វដែលកើតក្នុងទឹងនោះចុះឈ្មោះជាអ្នកជាន ជាលេខសួយទាំងអស់ទោះបុន្មានៗតក៏ពុំរួចជាព្រៃជានឹងគេទៀយសត្វណាកើតក្នុងពូជនោះ ទោះជាចេះវិជ្ជាការអ្វីៗប្តឹមានប្រាជ្ញាយ៉ាងណាក្តី ក៏តាំងខ្លួនពុំបាន ហៅថាសត្វឥតភព្វក្នុងលោកនេះឯង។

ច្បាប់ដែលថាមកនេះ ជាប់ចាទមួន់ទៅខាងអ្នកទាបប្រាកដមួយទៀតច្បាប់នេះ បើមាននៅក្នុងប្រទេសទីណាហើយអ្នកប្រាជ្ញណា និងគិតគេចឲ្យរួចចេញទៅពុំបាន បើចង់រួចចេញនោះ បានតែរត់ចោលស្រុកភៀសខ្លួនទៅនៅប្រទេសទីទៃឯទៀតៗ នោះទើបបានដូចនិទានលោកតាសុខពួងនោះឯង។

ទៀងភិក្ខុសុខជាពួងត្រួ

ឯទៀងនោះមានចៅពួងត្រួ១អាស្រ័យនៅក្នុងស្រុកលើទកស៊ីតាមភាសាអ្នកព្រៃ នៅយូរមកពួកពួងដូចគ្នាកើតស្អប់ចៅនោះ ទាំនាំគ្នាទៅប្តឹងមេកន្ត្រាញភូមិនោះ ចោទថាចៅពួងព្រៃចេះអាបធ្មប់ធ្វើអ្នកស្រុកឲ្យស្លាប់ជាច្រើន ឯមេកន្ត្រាញ

មានអំណោចឮថា ចេះអាបធ្មប់ដូច្នោះក៏ឲ្យគ្នាទាំដើរកាប់សម្លាប់
ឮងដែត្រូវទៀតចោទនោះ ទាំងបុត្រភរិយាព្រមទាំងពូជពង្ស
ទាំង៧ ជួនអស់ឥតសល់ នៅតែក្មេងម្នាក់ឈ្មោះចៅសុខ ចៅ
នោះអាយុប្រមាណជា១០-១១ឆ្នាំ ចៅនោះនៅចាំចំការស្រូវក្នុង
ស្រែព្រៃ បានដឹងជាមេកន្ត្រាញ្ញប្រើឲ្យសម្លាប់អាពុកម្តាយបង
ប្អូន មឹងមា យាយតាអស់ដូច្នោះ ក៏ភិតភ័យមហិមា រត់ទៅទ្បើង
ចុងឈើលាក់ខ្លួនពួនអាត្មា នឹងមែកឈើស៊ុមទ្រុមសម្ងំ ឯពួកមេ
កន្ត្រាញ្ញទាំសម្លាប់ពូជបោះអស់ហើយ ទាំដឹងថា នៅសល់កូន១
ទើបទាំនាំគ្នាទៅរកក្មេងនោះឯចំការស្រូវដើមឫនឹងសម្លាប់
ចោលឲ្យអស់ពូជ លុះទៅដល់ចំការ ទាំក៏ដើរទើរកតាមជ្រោះ
ជ្រលងតូមួយព្រៃសព្វអន្លើក៏ពុំឃើញ ទើបទាំនាំគ្នាវិលមកភូមិ
វិញ ឯចៅក្មេងពួននៅលើចុងឈើ កាលពួកនោះទៅរកក៏បាន
ឃើញគេកាន់ដាវកាន់កាំបិតចូលមករកខ្លួន ក៏ដឹងថាគេមកសម្លា
ប់អាត្មា ព្រោះក្មេងនោះដឹងច្បាប់ឮងថាមេកន្ត្រាញ្ញឲ្យសម្លាប់
ទាំងអស់ឥតសល់ ហេតុនោះទើបចៅក្មេងខំពួនលាក់ខ្លួននឹងប្រ
គាបឈើ ឱបមែកឈើនោះខ្ជាប់ លុះពេលយប់ស្ងាត់ចៅក្មេង
នោះចុះចាកព្រីកក្រានត់ចេញអំពីចំការ ដើរកាត់ព្រៃត្រងចុះ

មកភូមិក្រោម ចូលទៅសួមពួននឹងផ្ទះឮងម្នាក់នៅដើមភូមិ
ឯអ្នកផ្ទះនោះគេក៏អាណិតក្មេងនោះ ឲ្យបាយទឹកអស្រ័យហើយ
យកទៅលាក់ទុកក្នុងផ្ទះ ឯអាពួកមេកន្ត្រាញ្ញដើរកក្មេងនោះ
ពុំឃើញហើយ លុះថ្ងៃព្រឹមទ្បើង ទាតាមរកដល់ភូមិក្រោមទា
ដើរសុំបសួរនរកគ្រប់ផ្ទះ ឯអ្នកស្រុកក៏ឆ្លើយប្រាប់ថាពុំឃើញ
ទាំងអស់ ឯពួកនោះនៅសងប្រ័យ ក្រែងអ្នកស្រុកលាក់បិទបាំង
ទុក ទើបទាំនាំគ្នាទ្បើងទើមើលគ្រប់ផ្ទះ តែផ្ទះដែលចៅក្មេង
ទៅពួននោះ គឺនៅខាងដើមភូមិបង្អស់ ច្បាប់ឮងត្រូវទៅរកមនុ
សន្តនោះ គឺទើរកតែផ្ទះណាដែលនៅកណ្តាលគេ ឬចុងគេជា
ការមាំទាំឯត្រង់ផ្ទះនៅដើមភូមិក៏មិនសូវទំមានក្តីសងប្រ័យពេក
តែផ្ទះដែលក្មេងពួននោះ ទាពុំបានទ្បើងទើឲ្យមាំមួន លុះទាំរក
ពុំឃើញ ហើយទើបទាំនាំគ្នាវិលទៅជំរាបមេកន្ត្រាញ្ញនោះ
វិញ។

ឯអ្នកផ្ទះកាលបើពួកនោះវិលទៅអស់ហើយ ទើបនិយាយ
នឹងក្មេងនោះថា "បាឯងនៅនឹងយើងនេះយើងនឹងការពារពុំរួច
ទេ ព្រោះផ្ទះយើងនៅជិតនឹងមេកន្ត្រាញ្ញនោះ កាលណានឹង
ស្ងាត់គង់នឹងដឹងដល់ទាពុំខាន បើបាឯងចង់រួចជីវិត មានតែរត់ចុះ

ទៅនៅដែនខ្មែរ អើព្រឹកមិញនេះមានមេឃ្មុំក្រទេះខ្មែរគេ
ទៅស្រុកគេ បើដូច្នេះបាឯងខំរត់ទៅតាមរទេះខ្មែរនោះឲ្យ
ទាន់ សូមដោយសារគេទៅស្រុកក្រចេះចុះ"។ ឯក្មេងនោះឮ
ដូច្នោះក៏ជឿតាម ទើបសំពះលាអ្នកផ្ទះហើយខំរត់តាមរទេះ
ខ្មែរ ត្រដល់ទាន់នាកណ្តាលផ្លូវ ក៏ដើរក្រោយរទេះនោះទៅ
ដោយនឿយណាស់ពុំអាចនឹងដើរបាន ទើបទៀងជិះប្រែក
រទេះតោងក្រោយទៅ។ ឯនាយឃ្មុំបែរមកឃើញក្មេង
តោងរទេះជិះក្រោយដូច្នោះក៏ចុះមកសួរនិយាយភាសាឰងថា
"ចៅឯងជាកូនចៅនរណា បានជាមកតោងរទេះយើងនេះ"។
ឯចៅក្មេងនោះនិយាយប្រាប់ តាំងតែអំដើមដល់ចប់ឲ្យនាយ
ឃ្មុំនោះស្តាប់នាយឃ្មុំដឹងហើយក៏កើតសេចក្តីសង្វេគអាណិ
តពន់ពេកណាស់ ទើបថា "អើបើដូច្នោះចៅឯងទៅនៅនឹង
យើងចុះ យើងឥតកូនទេយើងយកបាឯងជាកូនធម៌ កាលដែល
គេគិតបៀតបៀនបានោះយើងទទួលជាភារៈ ចៅកុំជាទុក្ខ
ទៀយ" ថាហើយក៏ឲ្យក្មេងនោះជិះក្នងរទេះ បរទៅដរាបដល់
ស្រុកក្រចេះ នាយឃ្មុំក៏បរទៅទៅផ្ទះនៃអាត្មា ដល់ហើយក៏
ឈប់នៅ តាំងនាមក្មេងនោះហៅថាសុខព្រោះចៅនោះផុតពី

សេចក្តីទុក្ខ អំពីដែនមកទ្រង់ញាំងនោះហើយនាយឃ្មុំស្រឡាញ់
ចៅសុខទុកជាបុត្រនៃអាត្មា ឲ្យសិក្សាហិបង្ហាត់បង្រៀនចៅសុខ
ឲ្យចេះនិយាយភាសាខ្មែរបាន ចៅសុខក៏ខំឲ្យសិក្សាហិប្រតិបត្តិបំ
រើនាយឃ្មុំនោះ ពុំឲ្យមានសេចក្តីទន្ទៀសអ្វី១ទៀយលុះនៅ
មកនាយឃ្មុំឲ្យចៅសុខទៅនៅវត្តរៀនអក្សរខ្មែរចៅសុខ
ឲ្យសិក្សាហិរៀនសូត្រត្រទាល់តែបានសំរេចក្តីប្រាថ្នា លុះបាន១៥
ឆ្នាំ នាយឃ្មុំឲ្យបួសជាសាមណេរហៅថានេនសុខ លុះអាយុ
បាន២១វស្សា បិតាធម៌បំបួសជាភិក្ខុ ហៅថាលោកភិក្ខុសុខនៅ
ជាសុខសប្បាយដោយលាភសក្ការៈ ដែលបង្កើតមានក្នុងព្រះពុទ្ធ
សាសនានេះហោង។

"អើឯងស្តាប់មើលចុះ ទៀងនិទានអស់នេះគឺចប្បាប់ថា អ្នក
ណាមានទោសហើយទោសនោះអាចធ្លាក់ដល់កូនដល់ចៅអ្នក
នោះ ដែលគ្នាពុំដឹងពុំឮអ្វីទៀយមែនបើចប្បាប់នេះ មាននៅក្នុង
ស្រុកណាហើយលោកថាឲ្យរត់ចេញចាកស្រុកនោះឲ្យឆាប់
ទើបរកជ្រាជីវិតបាន ដូចលោកភិក្ខុសុខដែលសំដែងមកនេះ គួរ
ចូលចិត្តចុះ សំដែងមកក្នុងពាលវគ្គនេះ ចប់ដោយសង្ខេបតែ
ប៉ុណ្ណេះ"។ ឥតីនេះនឹងសំដែងក្នុងបណ្ឌិតវគ្គតទៅ។

បណ្ហិតវគ្គ

កូនសិស្សសួរគ្រូថា វើងមនុស្សពាលមានឱបាយកលនឹងមានអំណោចអាចបៀតបៀនយាយីមហាជនក្នុងព្រះនគរនេះ លោកគ្រូអធិប្បាយមកច្រើនវើងច្រើនបែប ខ្ញុំកនុណាបានស្តាប់ក៏ចូលចិត្តថា ពាលនេះគួរចៀសគួរវាងចាលខ្លាចវាហើយ ក៏ឯមនុស្សដែលលោកបញ្ញត្តិនាម ហៅថាអ្នកប្រាជ្ញនោះ តើមានលក្ខណៈយ៉ាងណា? មានកិរិយាដូចម្តេច?។

(គ) "ឱមនុស្សដែលហៅថាអ្នកប្រាជ្ញបាននោះ"។ យើងនឹងសួរទៅឯងវិញ ក្នុងចិត្តឯងតើសំគាល់រូបលោកអ្នកណាដែលគួរហៅថា អ្នកប្រាជ្ញបាន"។

"សូមទានខ្ញុំកនុណាសំគាល់ថា លោកអាចារ្យដែលចេះព្រះត្រៃបិដក១ លោកអាចារ្យដែលចេះព្រះកម្មដ្ឋាន១ លោកទាំង២ នេះហៅថាអ្នកប្រាជ្ញ?។

"អើឯងថានេះត្រូវដែរ តែមិនទាន់ចំក៏ឯលោកអ្នកចេះព្រះត្រៃបិដកព្រះកម្មដ្ឋាននោះ បើចេះហើយតែនៅមិនទាន់ទូន្មានខ្លួនឲ្យស្លូតត្រង់បាន នៅប្រកបដោយលោភៈ ទោសៈ មោហៈទីដ្ឋិ ខឹងឃោរឃៅពោលប្រទេចផ្តាសាទាយតែកាច់

មួលព្រះពុទ្ធភាសិត ពុំប្រព្រឹត្តតាមក្រឹត្យបន្ទាត់ព្រះវិន័យដាដើមយ៉ាងនេះ តើនឹងហៅថាអ្នកប្រាជ្ញបានឬដូចម្តេច"។

"កនុណា បើលោកចេះព្រះត្រៃបិដក ចេះព្រះកម្មដ្ឋានហើយចិត្តនោះនៅមានលោភៈ ទោសៈ មោហៈជាដើមយ៉ាងនេះ ក៏ពុំបានឆាប់ហៅថា ជាអ្នកប្រាជ្ញទៀយហៅថាពាលវិញ"។

"អើដូចយ៉ាងកបិលភិក្ខុ បួសក្នុងពុទ្ធសាសនាព្រះពុទ្ធកស្សបៈជាម្ចាស់នោះ គឺជាភិក្ខុចេះព្រះត្រៃបិដកចប់ទាំងប្រាំបីហ្មឺនបួនពាន់ ធ្វើជាអាចារ្យធំ តែពុំប្រព្រឹត្តតាមធម៌តាមវិន័យ ស្រដីកាច់មួលព្រះពុទ្ធវចនៈទៅផ្សេងៗ លុះអស់អាយុទៅ ក៏ធ្លាក់ទៅសោយទុក្ខវេទនាក្នុងមហានរកនរកទុក្ខអស់ពុទ្ធន្តរ១ លុះដល់ព្រះសម្មាសម្ពុទ្ធជាម្ចាស់យើង បានត្រាស់ក្នុងលោកនេះ នោះកបិលភិក្ខុបានទួចចាកជាតិជាសត្វនរក មកកើតជាត្រីមានពណ៌ដូចមាស តែមានមាត់នោះស្មុយ អសោចិទួទៅវើងនិទាននេះមានពិស្តារក្នុងគម្ពីរធម្មបទ ឯងស្តាប់មើលចុះ នេះលោកអាចារ្យចេះព្រះត្រៃបិដកហើយ នឹងថាអ្នកប្រាជ្ញបានឬមិនបាន" មួយទៀតខាងលោកដែលចេះព្រកម្មដ្ឋាននោះដូចយ៉ាងទេវទត្តត្រូវ គឺបានទៅបួសក្នុងសំណាក់ព្រះសម្មាសម្ពុទ្ធជាម្ចាស់ បានវៀនព្រះ

កម្មដ្ឋានស្តាត់ជំនាញ ញុំាងឈានលោកិយឲ្យកើតអាចសំដែងបាដិហារ្យ ដល់ក្រោយមកកើតលោភចិត្តប្រព្រឹត្តធ្វើលោហិតុប្បាទ ព្រមទាំងសង្ឃភេទកម្ម ជាកម្មយ៉ាងធំផងផែនដីមិនអាចទ្រទ្រង់ទុកបាន ក៏បើកស្រូបទំលាក់ចុះទៅសោយទុក្ខវេទនា ក្នុងមហាអវីចិនរកអស់ផែនដីនេះជាកំណត់ ទើរឯងនេះឯងស្តាប់មើលចុះទេវទត្តនោះ ជាមនុស្សពាលឬអ្នកប្រាជ្ញ"។

"កន្លងខ្ញុំស្តាប់បានហើយលោកចេះព្រះត្រៃបិដកចេះព្រះកម្មដ្ឋានចប់ក្តី តែចិត្តនៅពាលក៏ឈ្មោះថាពាលដដែល សូមទានន៍មន្តលោកគ្រូម្ចាស់ សំដែងលក្ខណធម៌អ្នកប្រាជ្ញឲ្យពិស្តារបន្តិចទៅមើលទាន"។ "ឱលក្ខណៈអ្នកប្រាជ្ញនោះបើនិយាយដោយតតិធម៌ទីញ្ញនោះ លោកចែកបុគ្គលជាពីរចំពូក គឺព្រះអរិយបុគ្គលទាំងឡាយ មានអង្គព្រះសម្មាសម្ពុទ្ធជាម្ចាស់ជាដើមនោះ ហៅថាជាអ្នកប្រាជ្ញប្រសើរទិសេសលើសលោក ចំពូក១កល្យាណបុថុជ្ជន គឺបុថុជ្ជនដែលមានគុណគឺបណ្ឌិតគប្បីនាប់នោះ ហៅថាអ្នកប្រាជ្ញប្រពៃចំពូក១។

ឯអ្នកប្រាជ្ញចំណែងខាងព្រះអរិយបុគ្គលក្នុងទីនេះយើងមិនសំដែងឲ្យពិស្តារទេ ព្រោះមាននៅក្នុងចំណែកតតិធម៌នោះ

ហើយ ក្នុងប៉ែកនេះសំដែងតែពួកអ្នកប្រាជ្ញ ចំណែកខាងកល្យាណបុថុជ្ជនចំពូក១ព្រោះជាគតិលោក"។

អរិយទ្រព្យ៧ប្រការ

ស. សី. ហិ. ខ្មិ. សុ. ចា. ប. អរិយទ្រព្យ៧ប្រការគឺសទ្ធា សេចក្តីជឿកម្ម និងផលនៃកម្មក្នុងព្រះពុទ្ធសាសនា១, សីល៥ ៦ ១០ ២២៨ ដំបទិសុទ្ធ១, អៀនខ្មាស់អំពើអាក្រក់១, សេចក្តីភ័យខ្លាចបាប១, កិរិយាត្រាប់ត្រង់នូវធម៌១, សេចក្តីបរិច្ចាគទានឬលះបង់ចោលនូវអំពើអាក្រក់១, បញ្ញាជាសម្ចាទិដ្ឋិ១, ធម៌៧ប្រការនេះមាននៅលើបុថុជ្ជនណាបុថុជ្ជននោះឯងហៅថា កល្យាណបុថុជ្ជនគឺនាប់ថាជាអ្នកប្រាជ្ញបាន។

សប្បុរិសធម៌៧ ប្រការ

១ ធម្មញ្ញុតា ភាវៈជាអ្នកស្គាល់នូវហេតុនៃផលមានស្គាល់ថា ទបស់នេះជាហេតុជាទីតាំងនៃផលនេះ។ ជាផលដ៏បង្កើតមកអំពីហេតុនេះជាដើម។

២ អត្ថញ្ញុតា ភាវៈជាអ្នកស្គាល់នូវផលនៃហេតុមានស្គាល់ថា សេចក្តីសុខនេះ ជាផលនៃហេតុនេះ សេចក្តីទុក្ខនេះ ជាផលនៃហេតុនេះជាដើម។

๓ អត្តញ្ញតា ភាវៈជាអ្នកដឹងខ្លួនថាយើងមានជាតិគោត្រត្រកូលយ៉ាងនេះ សក្តិយសសម្បត្តិបរិវារប៉ុណ្ណោះ ចំណេះវិជ្ជាគួរធម៌ត្រឹមប៉ុណ្ណោះៗ ហើយត្រូវប្រព្រឹត្តខ្លួនឲ្យសមគួរដល់ឋានៈដែលមាននៅយ៉ាងម្តេចៗនោះ ។

๔ មត្តញ្ញតា ទំនងជាអ្នកស្គាល់ប្រមាណក្នុងការស្វែងរកចិញ្ចឹមជីវិត ដោយផ្លូវសម្មាជីវៈនឹងប្រមាណក្នុងការបរិភោគល្មមគួរ ។

๕ កាលញ្ញតា បែបជាអ្នកស្គាល់កាលទៀងដ៏សមគួរក្នុងពេលប្រកបកិច្ចនោះៗ ។

๖ បរិសញ្ញតា របៀបជាអ្នកស្គាល់ប្រជុំជននឹងកិរិយាដែលត្រូវប្រព្រឹត្តក្នុងទីប្រជុំជននោះៗ ថាពួកនេះកាលចូលទៅរក តោងធ្វើកិរិយាយ៉ាងនេះ ត្រូវនិយាយយ៉ាងនេះជាដើម ។

๗ បុគ្គលបរោបរញ្ញតា សន្តានជាអ្នកស្គាល់នូវអធ្យាស្រ័យនៃបុគ្គលថា បុគ្គលនេះល្អគួរគប់ជាមិត្របុគ្គលនេះជាមនុស្សអាក្រក់ មិនគួរយកជាមិត្រជាដើម ។

សប្បុរិសធម៌ទាំង៧ នេះមាននៅលើបុគ្គលណាបុគ្គលនោះហៅថាជាអ្នកប្រាជ្ញពិតប្រាកដក្នុងលោកនេះ ។ មួយទៀត

សភាវៈធម៌ដែលនាំឲ្យប្រាសចាកក្តីចាក់ដោតគេឲ្យឈឺចាប់ផ្សេងៗ សេចក្តីមេត្តាករុណាសត្វ នាំសត្វឲ្យរួចចាកទុក្ខទោសបាន សេចក្តីបរិសុទ្ធចិត្តទៅក្នុងសត្តនិកាយ សេចក្តីទូន្មានសត្វឲ្យដើរផ្លូវល្អ គឺញុំាងពពួកសត្វឲ្យស្ថិតនៅក្នុងកុសលធម៌បាន សភាវធម៌ទាំងអស់នេះ ជារបស់នៃអ្នកប្រាជ្ញគួរចូលចិត្តចុះ ។

មួយទៀតអ្នកប្រាជ្ញនោះ បើនិយាយដោយយ៉ាងខ្លី គឺលោកស្រដីថា បុគ្គលឯណាទទួលខ្លួនឬសំគាល់ខ្លួនថាជាអ្នកល្ងង់នៅទៀយ បុគ្គលនោះឯងហៅថាជាអ្នកប្រាជ្ញទើញដូចមានបទបាលីថាៈ

ពាលោ មញ្ញតិ ពាលៃ្យ បណ្ឌិតោ វាបិ តេន សោ
ពាលោវ បណ្ឌិតមានិ សទៃ ពាលោតិ វុច្ចតិ ។

ជនឯណាដឹងខ្លួនជាពាលពិត ជននោះហៅបណ្ឌិតតាមនយោគ ជនឯណាតាំងតួថាប្រាជ្ញព្រោក ជននោះដាក់ហៅថាជាពាលធំ ។

(ស) "សូមទានពាក្យដែលហៅថាអ្នកប្រាជ្ញៗនេះសំដៅយកបញ្ញា ដែលចេះដឹងនោះឬៗសំដៅយកចិត្តចេតសិកណាទើញ? ។

(គ) "ឱអ្នកប្រាជ្ញនោះលោកក៏វាប់យកដួងបញ្ញាចេតសិក

ដែលពិចារណាដឹងទូទៅហើយប្រព្រឹត្តទៅតាមកាលដែលគួរ
ធ្វើបាន អ្នកប្រាជ្ញអាចដឹងហេតុពិតមិនពិតជាដើមនោះ ព្រោះ
លោកសំគាល់យកអាការៈដែលសំដែងចេញមកនោះ មកពិចារ
ណាត្រិះទិះមើលឯអាការៈនោះឯង អាចសំដែងប្រាប់មកឲ្យ
លោកជ្រាបបានដូចនិទានព្រាហ្មណ៍ចាស់ម្នាក់មានភរិយាក្រមុំ"។

ទើរឿងព្រាហ្មណ៍ចាស់មានភរិយាក្រមុំ

នាងភរិយានោះ ទាសហាយនឹងព្រាហ្មណ៍មួយទើបទាប្រើ
ព្រាហ្មណ៍ចាស់ជាស្វាមី ឲ្យត្រាច់ដើរទៅសូមទានគេឯស្រុក
ក្រៅ ព្រាហ្មណ៍ចាស់លុះអំណាចភរិយា ទើបស្ពាយបិនក្អាចេញ
អំពីគ្រឹហ យាត្រាទៅស្វែងលាភតាមនិស្ស័យថ្ងៃ១ នោះតា
ព្រាហ្មណ៍ដើរទៅដល់កណ្តាលព្រៃ អស់កំឡាំងណាស់ទើបឈប់
បរិភោគសត្វទៅខ្មៅតាកកាលតាព្រាហ្មណ៍លូកយកសត្វទៅពីក្រសោ
ប មិនបានរួតមាត់ឲ្យជិតដូចដើមទៀតាព្រាហ្មណ៍បរិភោគ
ហើយ ក៏ចុះទៅផឹកទឹកឯត្រពាំងទឹក។ ក្រោយនោះមានពស់
វែក១ ទាំងក្តៀនសត្វទៅនោះទាក៏លូនចូលទៅក្នុងក្រសោបនោះឯង
ឯតាព្រាហ្មណ៍ផឹកទឹកស្រេចហើយក៏ទ្បើងមក តាំងរួតមាត់ត្រ
សោបនោះខ្ជាប់ ហើយក៏ស្ពាយដើរទៅ។

គ្រានោះមានទុក្ខទេវតា១ អង្គុយលំតាព្រាហ្មណ៍ស្ពាយក្រសោប
ស្រោបអាសិរពិសនៅក្នុងនោះ ក៏ស្រែកប្រាប់ដាពាក្យបញ្ជា
ថា ហៃព្រាហ្មណ៍ដនាអើយ នែបើថ្ងៃនេះព្រាហ្មណ៍ឯងទៅមិន
ដល់ផ្ទះទេនោះព្រាហ្មណ៍ឯងនឹងស្លាប់កណ្តាលផ្លូវពុំខាន ថាបើ
ថ្ងៃនេះព្រាហ្មណ៍ឯងដើរទៅដល់ផ្ទះ នោះប្រពន្ធព្រាហ្មណ៍ឯង
នឹងស្លាប់ពុំខាន ឯតាព្រាហ្មណ៍កាលណាបានឮពាក្យទុក្ខទេវតា
និយាយប្រាប់ដាអាថ៌បញ្ញាដូច្នោះហើយ ទើបពិចារណាគិតមិន
យល់ក៏នឹងមានសេចក្តីភិតភ័យ ទោមនស្សក្រៃពេកណាស់តាំង
តែសោយសោកទៅតាមផ្លូវ ដើរទៅបានដល់ក្រុងពារាណសី
ចូលទៅកាន់សំណាក់បរមពោធិសត្វដាអ្នកប្រាជ្ញ ដែលដាប្រធា
នក្នុងព្រះនគរ។ ពោធិសត្វបានយល់ព្រាហ្មណ៍ចាស់ យំសោក
ដើរចូលមកដូច្នោះក៏សួរថា "ហៃព្រាហ្មណ៍អើយ! ហេតុអ្វីក៏បាន
ដាកើតទុក្ខ មុខដោរដលដោយទឹកភ្នែកដូច្នោះ? តាព្រាហ្មណ៍
ក៏ថ្លែងចែងសេចក្តីពីដើមដល់ចប់ ដំរាបប្រាប់ពោធិសត្វសព្វ
ប្រការ ពោធិសត្វឮដូច្នោះពិចារណាតាមពាក្យទេវតាដែលថា
បើថ្ងៃនេះព្រាហ្មណ៍ទៅមិនដល់ផ្ទះ ព្រាហ្មណ៍ឯងនឹងស្លាប់កណ្តាល
ផ្លូវបើទៅដល់ផ្ទះនោះថាប្រពន្ធនឹងស្លាប់ទៀហេតុស្លាប់នោះ

យល់ជាមានអាសិរពិស ពស់ទាំងចូលនៅក្នុងក្រសោបនេះ គឺថាបើ
ព្រាហ្មណ៍ទៅមិនដល់ផ្ទះគង់ព្រាហ្មណ៍ឃ្លានបាយ ហើយនឹងឈប់
ស្រាយមាត់ក្រសោបយកសត្វនិមិត្តតែព្រាហ្មណ៍លូកដៃទៅ
ពស់នោះនឹងចឹកដៃព្រាហ្មណ៍ៗ ក៏នឹងស្លាប់ប្រាកដ ប្រសិនបើជា
ព្រាហ្មណ៍ទៅដល់ផ្ទះវិញនោះព្រាហ្មណ៍គង់នឹងប្រគល់ក្រសោប
នោះ ឲ្យទៅភរិយានាងភរិយានឹងស្រាយមាត់ក្រសោប នឹងយក
ទបស់ទ្រព្យ លុះតែនាងភរិយាលូកដៃចូលទៅក្នុងក្រសោប
កាលណា ពស់នោះនឹងចឹកដៃនាងភរិយាដល់ខ្ទូទំមរណាកាលមិន
ខាន។

ពោធិសត្វពិចារណាត្រិះរិះអាការៈពាក្យទេវតាយល់ហេតុ
មានមិនសង្ស័យ ទើបប្រើឲ្យអ្នកបំរើយកក្រសោបព្រាហ្មណ៍
នោះ ទៅស្រាយមាត់នាទីវាលឯពស់ទែកនោះ និមិត្តតែមាត់
ក្រសោបនោះទសាយហើយ ទើបវាលួនចូលមកមួយរំពេច។

បណ្តាមហាជននឹងព្រាហ្មណ៍ចាស់នោះបានឃើញពស់ទែក
ចេញចាកក្រសោបដូច្នោះហើយនាំគ្នាឲ្យសព្វសាធុការសរសើរ
ប្រាជ្ញាបារមីនៃពោធិសត្វ ជាអនេកបរិយាយផ្សេងៗ ពោធិ
សត្វក៏ឲ្យអ្នកបំរើចាប់ពស់នោះយកទៅលែងទីព្រៃ ហើយ

ប្រាប់ព្រាហ្មណ៍ថា "តាឯងចូរមើលសេចក្តីអន្តរាយជីវិតតាឯង
ដោយពស់ទែកនេះចុះ"។ ព្រាហ្មណ៍ចាស់សំពះពោធិសត្វសរ
សើរថា "ខ្ញុំបាទបានរួចជីវិតក្នុងគ្រានេះ ក៏ព្រោះមកបាននឹង
នឹងលោកជាអ្នកប្រាជ្ញអាចរកសេចក្តីសុខបាន ខ្ញុំបាទពុំមានវត្ថុ
អ្វីជាឧត្តមសមគួរ នឹងបូជាតបគុណទៀយមានតែម្រាមដៃទាំង
១០ ខ្ញុំទំនាក់តបគុណលោកក្នុងគ្រានេះ"។

ពោធិសត្វសួរថា "ព្រាហ្មណ៍ឯងចាស់ជរាហើយនរណាប្រើតា
ឯងឲ្យសូមទានគេដូច្នោះ"។

ព្រាហ្មណ៍ជំរាបថា "ប្រពន្ធខ្ញុំបាទប្រើមក"។ នាង "ប្រពន្ធតា
ឯងនោះតើជា ស្រីចាស់ឬជាក្រមុំ?"។

"សូមទាននៅក្រមុំក្មេង"។

ពោធិសត្វពិចារណាអាការនោះទៀត ក៏យល់ថានាងនោះ
មានសហាយប្រាកដ ទើបថា "អើព្រាហ្មណ៍, នាងប្រពន្ធតាឯង
នោះ មិនសុចរិតនឹងតាឯងទេ បើតាឯងទៅដល់ផ្ទះ ហើយចូល
ទៅក្នុងទេលាត្រីស្ងាត់ទបស់ទ្រព្យ ដែលតាឯងបាននេះ ចូរតា
យកទៅឲ្យឃើញទាំងអស់គួរណាស់ទុកខ្លះ" ពោធិសត្វប្រដៅ
ព្រាហ្មណ៍នោះស្រេចហើយ ក៏ឲ្យដំណើរព្រាហ្មណ៍នោះទៅកាន់

ស្រុក។ តាព្រាហ្មណ៍ក៏លាពោធិសត្វដើរទៅកាន់ផ្ទះអាត្មាដល់
ទៅក៏ជួនទៀលាត្រីស្វាត់។

ឯមេព្រាហ្មណីជាប្រពន្ធនោះតាំងតែពីប្តីចេញទៅស្វែងរក
លាភបាត់ ទាក់តែងនាំចៅព្រាហ្មណ៍កំឡោះសហាយនោះមក
ដេកជាប្រក្រតី។

តាព្រាហ្មណ៍ទៅដល់ផ្ទះក៏យកប្រាក់ទៅលាក់នៅខាងជើង
សសរផ្ទះ ហើយទើបហៅប្រពន្ធឲ្យបើកទ្វារផ្ទះទទួលខ្លួន។
ឯមេនោះឮសូរប្តីមកដល់ក៏ភិតភ័យ ទើបបណ្តោះសហាយឲ្យ
ចុះទៅតាមបង្អួច ហើយទាធ្វើជាមាយាបើទ្វារម្ខ្ញុំទទួលព្រាហ្ម
ណ៍ឲ្យទៀងទៅ តាព្រាហ្មណ៍ទៀងដល់ផ្ទះហើយក៏និយាយចរចា
ប្រស្រ័យសុខទុក្ខតាមធម្មតា។ នាងភរិយាក៏សំណេះសំណាលសួរ
អំពីលាភដែលទៅស្វែងនោះទៀយៗ។ ព្រាហ្មណ៍លុះអំណាច
ភរិយាក្រមុំ ក៏ពុំអាចបិទបាំងប្រាក់ដែលខ្លួនកប់ទុកនោះទៀយ
ឆ្លើយប្រាប់ថា ខ្លួនបានប្រាក់មកកប់លាក់នៅជើងសសរផ្ទះ។

ឯសហាយ កាលទាចុះពីផ្ទះទៅនោះទាពុំរត់ទៅឯណាទៀយ
ទាលបនៅក្រោមផ្ទះចាំស្តាប់ព្រាហ្មណ៍ប្តីនឹងប្រពន្ធនិងនិយាយអ្វី។
លុះទាឮថាប្រាក់១០០កហាបណៈ ព្រាហ្មណ៍កប់លាក់នៅខាងជើង

សសរផ្ទះដូច្នោះ ទាក៏ទៅកកាយយកបានទាក៏លួចយកទៅផ្ទះទា
ហោង។

ព្រាហ្មណ៍ចាស់និងភរិយាក៏ដេកនៅតាមបន្ទៃលុះព្រឹកឡើង
ព្រាហ្មណ៍ភ្ញាក់ចាកដំណេក ដើរទៅមើលប្រាក់ដែលខ្លួនកប់លាក់
នោះ ក៏ពុំឃើញប្រាក់នោះ ព្រាហ្មណ៍តែតទុក្ខមហិមាគិតថា
"សេចក្តីអន្តរាយអញ្ចឹងដល់មកទៀតហើយ បើដូច្នេះមានតែ
ទៅរកលោកអ្នកប្រាជ្ញនោះ ឲ្យលោកជួយរកប្រាក់ដែលអា
នោះលួចយកទៅនោះទើបបាន" គិតហើយតាព្រាហ្មណ៍ក៏ទៀប
អាត្មា ដើរទៅកាន់សំណាក់បរមពោធិសត្វឯក្រុងពារាណសីដល់
ហើយក៏ជំរាបសេចក្តីតាំងអំពីដើមដល់ចប់សព្វប្រការ។

ឯពោធិសត្វ បានស្តាប់ព្រាហ្មណ៍ថ្លែងសេចក្តីដូច្នោះហើយ
ទើបនិះគិតអាការចោរលួចប្រាក់នោះក៏យល់ដោយប្រាជ្ញមួយ
រំពេច ទើបប្រាប់ព្រាហ្មណ៍ថា "តាឯងទិលទៅផ្ទះទិញប្រាប់ប្រ
ពន្ធតាឯងថា ខ្លួនតាឯងបានបន់ទេវតាថា បើខ្លួនបានមកដល់
ស្រុកសុខសប្បាយកាលណា នឹងធ្វើបុណ្យគ្រឹនមន្តព្រាហ្មណ៍ប្រាំ
មួយនាក់មកឆាន់ ចំណែកខាងតាឯង៣ នាក់ចំណែកខាងប្រពន្ធ
៣នាក់ ឆាន់៣ ថ្ងៃតែឲ្យផ្តាស់រូបព្រាហ្មណ៍ដែលឆាន់នោះកុំឲ្យ

យកដដែលក្នុងថ្ងៃដើម៦ រូប ថ្ងៃទី៣ ឲ្យផ្លាស់និមន្តព្រាហ្មណ៍៦
រូបទៀតមកឆាន់ ថ្ងៃទី៣ ឲ្យផ្លាស់និមន្តព្រាហ្មណ៍ឯទៀត ៦
រូបទៀតមកឆាន់ហើយតាឯងចាំមើលព្រាហ្មណ៍ខាងប្រពន្ធនោះ
ជាទាំផ្លាស់រូបទាំង៣ ឬៗយ៉ាងណានោះបើព្រាហ្មណ៍ណាជា
សង្ឃទាំៗ និងនិមន្តមកឆាន់ដដែលមិនផ្លាស់ទេ បើរូបណានៅ
ឆាន់ទាំង៣ ថ្ងៃរូបនោះហើយជាសហាយរបស់ទា ចូរតាឯងកំណ
ត់ទុកក្នុងចិត្ត ហើយមកប្រាប់យើងជាឆាប់យើងនឹងទៅចាប់តួ
អាចោរលួចប្រាក់នោះឯង"ៗ ពោធិសត្វប្រាប់ឱបាយសព្វប្រ
ការហើយ ក៏ឲ្យព្រាហ្មណ៍ចាស់នោះវិលទៅទីលំនៅវិញៗ
ព្រាហ្មណ៍ក៏លាពោធិសត្វទៅផ្ទះវិញ ដល់ហើយក៏ថ្លែងសេចក្តី
នោះប្រាប់នាងភរិយា តាមពាក្យនៃពោធិសត្វសព្វប្រការៗ
ឯនាងភរិយាក៏ធ្វើតាម គឺចាត់ចែងភោជនាហារស្រេចហើយ
ក៏និមន្តព្រាហ្មណ៍កំទ្បោះ ជាសហាយនោះមកឆាន់ទាំង៣ ថ្ងៃតែ
រូបព្រាហ្មណ៍ឯទៀតៗនោះផ្លាស់តាមបង្គាប់ព្រាហ្មណ៍នោះឯងៗ
ឯព្រាហ្មណ៍ចាស់ កាលណាបើឃើញព្រាហ្មណ៍កំទ្បោះខាងប្រពន្ធ
មកឆាន់ទាំង៣ ថ្ងៃដូច្នោះ ក៏កំណត់កត់ចាំរូបចាំឈ្មោះ ហើយយក
សេចក្តីនោះទៅជំរាបដល់បរមពោធិសត្វៗ ក៏ប្រើឲ្យអ្នក

បំរើទៅចាប់យកព្រាហ្មណ៍កំទ្បោះនោះមក តំរាមសួរតាម
ហេតុពិទ្ទុព្រាហ្មណ៍កំទ្បោះពុំអាចប្រកែកគេចបាន ក៏ទទួលសារ
ភាពជាចោរមែន ទើបទៅយកប្រាក់ដែលខ្លួនលួចនោះ មក
ប្រគល់ឲ្យព្រាហ្មណ៍ចាសវិញ សូមទោសនឹងបរមពោធិសត្វៗ
ក៏តិះដៀលជាអនេកបរិយាយ ហើយទូន្មានឲ្យលះបង់ចោលនូវ
អំពើពុតពាលហើយលែងឲ្យវិលទៅស្រុកវិញៗ ព្រាហ្មណ៍បាន
ប្រាក់វិញក៏សរសើរប្រាជ្ញានៃពោធិសត្វ ហើយតម្កល់នូវបរម
ពោធិសត្វ ជាគ្រូអាចារ្យចាប់ដើមពីថ្ងៃនោះមកៗ

រឿងរ៉ាវនេះមានសេចក្តីពិស្តារក្នុងព្រះគម្ពីរ យើងទាញ
យកមកសំដែងនេះតែជានិយសង្ខេប ជាបែបឲ្យយើញ្ញថា
លោកអ្នកមានប្រាជ្ញាពិចារណាតាមអាការៈដែលចេញ្ញមកនោះ
ពិចារណាដេញ្ញរកហេតុរកបច្ច័យ ទាល់តែការនោះច្បាស់ទៀ
ងប្រាកដដូចសំដែងមកនោះៗ

មួយទៀត រឿងអ្នកប្រាជ្ញពីបុរាណដែលមានមកក្នុងគម្ពីរ
បាលីដោយពិតនោះ យ៉ាងដូចអង្គព្រះមហោសថបរមពោធិ
សត្វក្តី ឯងគប្បីដឹងថាជាអ្នកប្រាជ្ញប្រសើរទិសេសចុះៗ

មែនពិត ឯអ្នកមានប្រាជ្ញាឆ្លាសទាំងនៃនោះ មិនភ្លើភាន់សតិ

ទៅផ្ទាស អាចគេចកែខ្លួនបានក្នុងប្រជុំជនឬការដែលមានដល់
មកមួយរំពេច ដូចនិទានមាន់ចែកែខ្លួនផុតអំពីសត្វសំពោច
បាន ។

រឿងសត្វសំពោចនឹងមាន់ចែ

មានសត្វសំពោច១ ដើរទៅឃើញមាន់ចែទំនៅលើប្រគាប
ឈើ ហើយសំពោចណើចង់ស៊ីមាន់ទើបនិយាយជាកលឧបាយមុ
សាទាំងថា "នែមាន់ចែជាសំឡាញ់អើយ! អើឥឡូវអញកាន់ព្រះ
អាជ្ញា ព្រះមហិសរ្យាធិបតី ទ្រង់ត្រាស់ប្រើឲ្យប្រកាសប្រាប់
អស់បណ្តាពួកសត្វដែលជាពៀរសត្រូវ នឹងគ្នានោះថាឲ្យព្រម
ព្រៀងជានឹងគ្នា ចាប់ដើមពីថ្ងៃនេះទៅកុំឲ្យមានសត្វណាយាយី
គ្នាទៀយ នែមាន់ចែយើងបានសុខសប្បាយហើយ ព្រោះព្រះ
ជាម្ចាស់លោកប្រាសតាំងច្បាស់ថ្កើងថា ឲ្យយើងជានឹងគ្នាឥឡូវនេះ
ខ្ញុំយល់ថា បាឯងក៏មកជាសំឡាញ់ដូចចង់ប្អូនគ្នាពិតៗ ចូរឯងចុះ
មកឲ្យគ្នាឱបថើបជាការមេត្រីបន្តិចទៅអេះ"។

ឯមាន់ចែមានប្រាជ្ញាទាំងនឹកតបភ្លាមទៅថា "អើបងសំពោច
បងឯងកាន់ព្រះរាជអាជ្ញាព្រះជាម្ចាស់មកបង្គាប់ថា ឲ្យយើងជា
នឹងគ្នានេះ ជាការល្អនិសេសណាស់ហើយបង ខ្ញុំយើញបងឯង

ហើយក៏មានចិត្តស្រឡាញ់ចង់ចុះទៅទទួលសេចក្តីស្និទ្ធស្នាលស្មេ
ហានឹងអ្នកបងដែរ តែការនេះឈប់សិនចុះ ព្រោះទីនេះមានឆ្កែ
មួយទាំនៅជាមួយនឹងខ្ញុំនេះ ឥឡូវទៀទៅរកស៊ីក្រៅបាត់ពុំទាន់
មកដល់នៅឡើយ យើងចាំជុំគ្នាទាំង៣ ប្រាណ ហើយសឹមយើង
ជួបគ្នានឹងបានក្រសោបឱបគ្នា ជាការមេត្រីយ៉ាងធំតែម្តង" លុះ
មាន់ចែនិយាយដូច្នោះហើយ ធ្វើជាបែរមើលទៅទិសខាងដើង
ហើយស្រែកថា "បងឆ្កែមកហើយ អើបងសុនខអញ្ជើញបោ
លចូលមកឲ្យឆាប់ តើតបងសំពោចគេមកនៅរង់ចាំបងឯង"។
ឯសំពោចឮថា ឆ្កែមកដូច្នោះហើយក៏ភិតភ័យ ព្រោះខ្លួននឹងឆ្កែ
ជាសត្រូវនឹងគ្នាទើបម្ចាស់ចេញអំពីទីនោះចូលព្រៃទៅ។
មាន់ចែក៏ទឹងតែបង្កើថា "បងសុនខចូរមកឲ្យឆាប់ៗបងសំពោ
ចកុំអាលទៅណាឈប់សិន បងសុនខគេមកដល់ហើយ"។
ឯសំពោចក៏ឆ្លើយថា "អាជ្ញាក្តៅណាស់នៅមិនបានទេ" ថាហើយ
ក៏រត់ចូលព្រៃទៅ។

រឿងនេះឯងស្តាប់មើលចុះ មាន់ចែមានប្រាជ្ញស្គាល់អាការ
សំពោចកុហកមុសាទាំទហើយ តើស្គាល់អាការ:កុហកបានមួយរំពេ
ចពាក្យមាន់ចែស្រែកឡកឲ្យសំពោចថា "អាចោលមេរ្យាត

ចេះមកពោលពាក្យថា ឯងកាន់ព្រះទាជាមកប្រកាសថាឲ្យសត្វដែលទាសឹកសត្រូវនឹងគ្នានោះ ត្រូវទៀបជានឹងគ្នាតែអញនឹងឯង ឯងត្រង់ឆ្កែនឹងឯងត្រឡប់ជាមិនសាមគ្គីនឹងអញ អាណាជឿឯងបានពាក្យមិនសាធារណៈទួទៅយ៉ាងនេះ ។

(និទាននេះមានដំណាលក្នុងក្បួនបារាំងសែស)

ទៀងសត្វតន្ត្រីរបស់ព្រះឥសូរ

មានសត្វតន្ត្រី១ ជាទីគាប់ព្រះទ័យនៃព្រះឥសូរៗ ស្រឡាញ់ទាប់អានជាទីទុកព្រះទ័យ ឯសត្វតន្ត្រីនោះបើចង់បានអ្វីៗក្តីប្តូទាចង់ស៊ីសាច់សត្វណាក្តី ទាទូលព្រះឥសូរថា ទាយល់សុបិនត្រូវស៊ីសត្វនេះឯព្រះឥសូរក៏ចេះជឿតាម ហៅសត្វនោះមកឲ្យទាស៊ីតែទៀងៗ ក៏បណ្តោសត្វទាំងឡាយមានគោ ក្របីជាដើម តែតក្តៅក្រហាយនឹងសត្វតន្ត្រីនោះមហិមា តែពុំហ៊ានថាអ្វី ព្រោះខ្លាចអំណាចព្រះឥសូរជាម្ចាស់លើសសត្វក្នុងលោកនេះ ។

ថ្ងៃ១ សត្វតន្ត្រីនោះទាចង់ស៊ីសាច់ស្តេចដំរីសទើបទាទូលព្រះឥសូរថា ទាយល់សុបិនត្រូវទៀសាច់ស្តេចដំរីស ឯព្រះឥសូរក៏ជឿតាម ទើបឲ្យបំរើទៅប្រាប់ដំរីសម្តាយនឹងកូនថា ឲ្យទៅលាងខ្លួនឲ្យស្អាតហើយឲ្យចូលមកក្នុងទៀលាព្រឹកនេះ ឲ្យសត្វតន្ត្រី

គេស៊ី តែឯតគេយល់សុបិនត្រូវត្រង់ទូបខ្លួនហើយ ឯដំរីសម្តាយនឹងកូនកាលណាបើឮថា ព្រះឥសូរឲ្យហៅខ្លួនទៅ ឲ្យសត្វតន្ត្រីស៊ីដូច្នោះហើយ ក៏ភិតភ័យនឹងសេចក្តីស្លាប់នោះមហិមា នាំគ្នាសោកទីយោកទៅផ្ទះៗ ពុំដឹងបើនឹងរកលោកអ្នកឯណាមេត្តាជួយកែដោះជីវិតនៃអាត្មាបាន ហើយក៏នាំគ្នាដើរចុះទៅក្នុងស្រះ ដើម្បីនឹងជូតទឹកដុំសលាងកាយ ។

គ្រាកាលនោះ មានសត្វទន្សុយមួយទំនៅលើមែកឈើ បានឃើញដំរីម្តាយនឹងកូនដើរយំសោកដូច្នោះហើយ ក៏សួរទៅថា "នែដំរីសអ្នកមានទុក្ខទោមនស្សព្រោះហេតុអ្វី? ឯដំរីសម្តាយនឹងកូនក៏ថ្លែងសេចក្តីទុក្ខនោះប្រាប់ទន្សុយ តាំងអំពីដើមដល់ចប់សព្វប្រការ ។ ឯទន្សុយឮដូច្នោះហើយក៏ថា "ឱព្រះឥសូរ លោកម្តេចក៏ប្រកបទៅដោយឆន្ទាគតិគំរៀងច្បាប់ លំអៀងសេចក្តីទៅតាមសេចក្តីស្រឡាញ់ ទៅជឿស្តាប់តែពាក្យសត្វតន្ត្រីឲ្យយាយីគេឯទៀតដូច្នោះ" ។ ដំរីសក៏ព្រមតាម ហើយឲ្យទន្សុយដុះទំលើកប្រាលកូនដំរីស ចរទៅកាន់សំណាកព្រះឥសូរឮដ៏ភ្លុំកែលាសមហាស្តាន ដល់ហើយទន្សុយក៏ចុះចាកកប្រាលនៃដំរីសចូលទៅទំទៀបបល្ល័ង្កទីនាងព្រះឥសូរហើយទូលថា "បពិត្រ

ព្រះអង្គដាក់ពូលលើសលោក ព្រះអង្គមានការអ្វីបានជាទ្រង់ឲ្យ
ហៅដំរីសជាបាវខ្ញុំទូលព្រះបង្គំមកនេះ មានហេតុភេទយ៉ាងណា
ព្រះករុណា"។ ព្រះឥសូរក៏ឆ្លើយថា "អើទីទុយបាវឯងនេះ ត្រូវ
ដល់សេចក្តីស្លាប់ហើយក្នុងថ្ងៃនេះឯង តែសត្វតន្ត្រីយល់សុបិនថា
ត្រូវឯបរិភោគសាច់ដំរីស ហេតុនោះទើបយើងឲ្យហៅដំរីសជា
បាវឯងមកឲ្យគេស៊ី"។

ទីទុយតបថា "សូមទានឯកិរិយាយល់សុបិនរបស់សត្វតន្ត្រី
នោះ ជាទៀងពិតប្រាកដព្រះអង្គយកជាប្រមាណណាស់ទៅ
ឬយ៉ាងម្តេច?។

"អើទីទុយ សត្វតន្ត្រីនោះគេយល់សុបិនហើយសុបិននោះមិត្ត
ទៀងពិតណាស់ យើងយកជាប្រមាណបាន"។ "ក្រាបទូលខ្ញុំទូល
ព្រះបង្គំ ក៏ដើរតាមព្រះបន្ទូល ដែលទ្រង់ដើរសុបិនសត្វតន្ត្រី
នោះ ដំរីសបាវខ្ញុំព្រះករុណាវិសេសក៏គួរដល់ស្លាប់ហើយ ខ្ញុំម្ចាស់
នាំមកថ្វាយ ឲ្យទ្រង់ប្រទានដំរីសឲ្យសត្វតន្ត្រីគេបរិភោគចុះ
តែខ្ញុំល្អងធូលីព្រះបាទយប់មិញនេះ មានធុនៈដើរចាប់ក្តាមបរិ
ភោគ ពុំបានទទួលទានដំណែកបានមួយស្រទៀតសិន ហើយខ្ញុំ
នាបាវទៅឲ្យសត្វតន្ត្រីនោះគេស៊ី" ថាហើយទីទុយក៏ធ្វើជាធ្វេច

ភ្នែកសម្លឹងដេកបន្តិច ទីទុយក៏ធ្វើជាភ្ញាក់ទៀងហើយពត់ខ្លួនពត់
ប្រាណសិតស្លាប ធ្វើកិរិយាវិកនាយហើយទូលព្រះឥសូរថា
"សូមទ្រង់ព្រះមេត្តាប្រោសខ្ញុំម្ចាស់ទទួលទានដំណែកអំបាញ់
មិញនេះទៅ យល់សុបិនល្អណាស់ ជាសុបិនមង្គលហៅសុភនិមិត្ត
។ ព្រះឥសូរក៏សួរថា "បាឯងយល់សុបិននោះដូចម្តេច ចូរនិយា
យទៅមើល? ទីទុយក៏ទូលថា "សុបិនខ្ញុំម្ចាស់នេះសេចក្តីប្លែក
ណាស់ ទៅជាមិនហ៊ាននិយាយផង"។ "អើឯងនិយាយទៅមើល
សុបិនឯងនោះយ៉ាងណា?។ "សូមទាន សុបិននោះឃើញថា
សម្តេចព្រះនាងឱមាភោគវតី ជាព្រះទាជមហេសីល្អងធូលីព្រះ
បាទក៏ប្រោសប្រទានឲ្យមកជាភរិយាខ្ញុំ សុបិនខ្ញុំនេះទៀងពិត
ប្រាកដណាស់ យកជាប្រមាណបានបើដូច្នេះសូមល្អងធូលីព្រះ
បាទ ហើយព្រះនាងឱមាភោគវតីនោះមក ព្រះទាជទានឲ្យខ្ញុំ
ទុកជាព្រះកែន្តីនៃព្រះករុណាវិសេស"។ ព្រះឥសូរឮដូច្នោះ
ក៏តូចព្រះទាជហឫទ័យ ទើបត្រាស់ថា "អាឯងយល់សុបិននេះតែ
ផ្តាសទេ យើងនឹងយកជាប្រមាណពុំបាន នឹងជើរស្តាប់ពុំបានទេ
អាទីទុយអើយ"។ ទីទុយតបថា "ក្តីយល់សុបិនខាងទូលព្រះបង្គំ
ព្រះអង្គថាយកជាប្រមាណពុំបាន ចុះខាងសត្វតន្ត្រីនោះ ម្តេចក៏

ព្រះអង្គជឿស្តាប់យកជាប្រមាណបាន? អើបើសុបិនខ្ញុំមិនពិត សុបិនសត្វតន្ត្រីនោះក៏មិនពិតដូចគ្នា ទិសិយសត្វសកុណជាតិដូចគ្នា សូមព្រះអង្គកាត់សេចក្តីនេះឲ្យបានប្រកបដោយយុត្តធម៌ទាំងសងខាងឲ្យទាន។ ព្រះឥសូរឮទីទុយស្តីដូច្នោះហើយក៏ទាញ់ទាល់ព្រះហឫទ័យណាស់ ទើបត្រាស់ថា "អើបើដូច្នោះ ចូរឯងនាំយកដីវិសជាបាវឯង ទិលទៅកាន់ទីលំនៅឯងវិញចុះ ការនេះយើងលើកលែងគ្នាតែប៉ុណ្ណោះ"។

ទីទុយក៏ក្រាបថ្វាយបង្គំលា នាំដីវិសទៅទីលំនៅបានជួបគ្នាម្តាយនឹងកូន នៅជាសុខសប្បាយរួចរំពីអន្តរាយជីវិត ព្រោះបានសេពគប់ទៅលើមិត្ត តីទីទុយជាអ្នកប្រាជ្ញ អាចដោះទុក្ខបានដោយប្រការយ៉ាងនេះ។

ទើរឿងនិទាននេះឯងស្តាប់មើលចុះការអ្នកមានបញ្ញានោះហៅថា អ្នកប្រាជ្ញបានក្នុងលោកយើងនេះ។

ទីអើយទីទុយ រូបរាងទុយមុយ អាក្រក់តែកាយ តែត្រង់បញ្ញាជ្រះថ្លាពណ្ណនាយ អាចកែដោះស្រាយ តព្រះឥសូរ។ ឥសូរភូមិន្ទកាន់ខាងសុបិន តន្ត្រីបក្សី ទាំតែងតម្រូវ ថាត្រូវដីវិ ធ្លាក់ជាចំណីនៃទាភោក្តា។ ទីទុយបញ្ចប់ យកសប្តីនឹងសប្តី លើកទៀងតាំ

ទានយកមហេសី តីនាងឱមា ផ្ញាញ់ព្រះប្រាជ្ញា មហិសរនាចេញ ហោង។

តម្រាលោកិយស្តីស្មើភ្នែ

ទើរឿងក្មេងកំព្រានឹងព្រះចៅដែនដី

មានកូនក្មេង១ នាក់អាយុ១៥ ឆ្នាំជាក្មេងកំព្រាឥតមានមាតាបិតារក្សា ក្មេងនោះទៅនៅដោយសារនាងនាយពិសេស តីនាងគ្រួសំរាប់ធ្វើក្រយាស្មោយអ្នកស្តេច ឯនាយពិសេសគេក៏អាណិតមេត្តាឲ្យនៅហើយគេប្រើឲ្យលាងចាន លាងថាស ជូតសមស្លាបព្រាឲ្យប្រាក់ខែក្នុងមួយខែជាប្រាក់ ៥៦ កាក់លម្មការសោហ៊ុយបាន ក្មេងនោះខុសប្រហាក់ធ្វើក្នុងមុខក្រសួងរបស់ខ្លួនបានប្រាក់តែរាល់ខែទៀងមក។ ឯព្រះបរមខត្តិយាព្រះចៅដែនដី ស្តេចតែងយាងមកទតការក្នុងនាងពិសេស បានទ្រង់យល់ក្មេងនោះ ធ្វើការស៊ីឈ្នួលលាងចាននោះទើរៗ។ ថ្ងៃ១ស្តេចទ្រង់យាងមកនាងពិសេស យល់កូនក្មេងកំពុងតែលាងចាននៅក្រៅនាង ស្តេចត្រាស់សួរថា "ចៅឯងស៊ីឈ្នួលលាងចានសព្វថ្ងៃនេះមានប្រាក់ប៉ុន្មានហើយ"។ ក្មេងនោះឆ្លើយថា "សព្វថ្ងៃនេះខ្ញុំមានស្មើគ្នានឹងស្តេចដែនដី"។ ស្តេចត្រាស់ថា "ការដែល

ទកស៊ីឈ្នួលគេក្នុងលោកនេះ គឺការស៊ីឈ្នួលលាងចាន មានសម្បត្តិ
ស្មើនឹងយើងជាម្ចាស់ផែនដីផ្ទៃក្រោមនេះ"។ ក្មេងនេះក៏អធិ
ប្បាយថា "ខ្ញុំស៊ីឈ្នួលគេសព្វថ្ងៃនេះ ក្នុង១ ខែគេឲ្យ ៥៦ កាក់
ក៏ពិតមែន តែការដែលទទួលទានបាយក៏ត្រឹម១ ផ្អែតទទួលទាន
ដំណេកក៏ត្រឹម១ ពេល ឯអ្នកស្តេចដែលមានសម្បត្តិច្រើនរាប់
មិនអស់នោះសោត ក្នុង១ ថ្ងៃក៏គង់សោយព្រះក្រយាស្ងោយត្រឹ
មតែ១ ផ្អែតដូចគ្នានឹងសោយឲ្យលើសអំពីនោះទៅក៏ទេ នឹង
ការដែលទ្រង់ផ្ទំសោតក៏ទ្រង់ផ្ទំត្រឹម១ ពេលដូចគ្នា នឹងឲ្យលើស
លែងពីនោះទៅក៏ទេ ហេតុនោះទើបខ្ញុំថាខ្លួនខ្ញុំមានសម្បត្តិ
ស្មើនឹងម្ចាស់ផែនដីដែរ"។ ឯមហាកុ្សត្រាធិបតីបាន ស្តាប់ពាក្យ
ក្មេង ទាំងអធិប្បាយប្រាប់ហេតុយក១ ផ្អែតជាប្រមាណដូច្នោះ
ហើយ ក៏ទ្រង់យល់ថាពិតថាមែនប្រាកដណាស់ ទ្រង់ពិចារណា
មើលហេតុទៅក៏ពុំមានខុសអំពីគ្នា គឺអ្នកក្រក៏ស៊ីត្រឹម១ ផ្អែត
អ្នកមានក៏ស៊ីត្រឹម១ ផ្អែតដូចគ្នា ស្តេចមានព្រះហឫទ័យស្រឡាំ
ញ៉ាំពាក្យក្មេងនោះក្រៃពេក ទើបទ្រង់ប្រទានមានប្រាក់សម្ពត់
ខោអាវឲ្យទៅក្មេងនោះ ហើយទ្រង់ចារឹកពាក្យក្មេងនោះ
ហៅថា ពាក្យអ្នកប្រាជ្ញបានក្នុងលោកនេះ។

មានរឿង ១ ទៀត

ឈ្មោះថាតម្រាស្រែបតបតក្អា

ទៀងព្រះចៅផែនដីនឹងក្មេងឃ្វាលក្របី

មានមហាកុ្សត្រាធិបតី១ ព្រះអង្គ ស្តេចនាំពួកសេវិកាមាត្យ
មុខមន្ត្រីទាំងឡាយ សឹងនាំគ្នាទៀបក្បួនហែស្តេចទៅតាមមុខ
ជាំវ លុះទៅដល់ទីទួល១ ជាទីសមគួរដាក់ឈប់អាស្រ័យបរិភោ
គភោជនាហារ នាទៀលព្រឹក ទើបស្តេចឲ្យពួកអ្នកពិសេសដាំ
ស្លចំអិនក្រយាស្ងោយរង់ចាំនៅ ឯព្រះអង្គឯងនឹងពួកទាហាន
សេះ ក៏បរសេះចេញទៅដេញសត្វ បាញ់សត្វម្រឹគម្រឹគាតាម
ជួរព្រៃ ឯពួកមន្ត្រីក៏នាំគ្នាជិះសេះបរតាមស្តេចទៅ ឯសេះ
ស្តេចនោះលឿនលើសសេះពួកមន្ត្រី ទើបបរទៅដាច់អស់
សេះទាំងពួង ពួកមន្ត្រីតាមពុំទាន់ ស្តេចបរព្រះទីនាំងចូលព្រៃ
ចេញទៅលទង្វើងផ្លូវទៅតែ១ ព្រះអង្គឯង លុះពេលថ្ងៃត្រង់
ស្តេចរកផ្លូវនឹងទីលមកទីជម្រំដែលចតនោះពុំឃើញ តែឃ្លា
នព្រះស្ងោយពន់ពេក ស្តេចខំបរសេះព្រះទីនាំងកាត់ព្រៃធំ
ចេញទៅដល់ទីមាត់បឹង១ បានឮសព្ទត្រដោកគោក្របី នឹងសំ
ឡេងក្មេងឃ្វាលក្របីទាំនិយាយគ្នា ទើបទ្រង់បរសេះកាត់តម្រង់

ទៅទីនោះលុះដល់បានឃើញក្មេងគង្វាលគោក្របីម្នាក់ ទើបត្រាស់សួរក្មេងនោះថា អើអានាង ទីទួលគោកចែងកន្លែងតែតែងមកឈប់កាក់ដាក់អាស្រ័យនោះ ចៅឯងបានដឹងបានស្គាល់ខ្លះឬទេ។

ឯក្មេងពុំស្គាល់ជាស្តេច នឹកស្មានជាមនុស្សដទៃផ្តាសទើបនិយាយប្រាប់ថា "ទីទួលគោកចែងនោះខ្ញុំបាទស្គាល់ច្បាស់ណាស់ទៅពីនេះទៅមិនឆ្ងាយប៉ុន្មានទេ ចូរអ្នកបរសេះទៅខាងទិសខ្តួននោះចុះ ថាហើយក្មេងនោះលើកដៃចង្អុលប្រាប់ផ្លូវទៀ។ ឯមហាក្សត្រាធិបតី ស្តេចនឹងទៅតែឯងក្រែងវង្វេងផ្លូវទៀតប្រុះហឫទ័យចង់បានក្មេងនោះ ជូនទៅជាមួយផងទើបត្រាស់ថា "អានាងឯងជិះសេះខាងក្រោយយើងជូនយើងទៅឲ្យដល់ទីទួលគោកចែងនោះ សូមឯងវិលមកវិញ យើងនឹងឲ្យប្រាក់ឯងជាទង្វាន់ថ្លៃជូនគ្នានោះ"។

ក្មេងនោះក៏ព្រមជូនផ្លូវ ទើបវាទៀងជិះសេះខាងក្រោយឲ្យស្តេចបរចរទៅតាមមាគា ខ្លួនវាជាមគ្គុទ្ទេសក៍ចង្អុលផ្លូវបរទៅតាមលំដាប់វាលព្រៃ។ លុះដល់កណ្តាលផ្លូវស្តេចទ្រង់ត្រាស់ថា "អើអានាងឯងនៅស្រុកក្រៅនេះ ឯងបានស្គាល់ស្តេចជាម្ចាស់ផែនដីឬទេ? "បាទទេខ្ញុំបាទមិនដែលស្គាល់ទេបង មិនដែលឃើញសោះ អ្នកស្តេចនោះឮតែម៉ែឱ្យប្រាប់ថាហ្លួង ហ្លួងនោះពុំដឹងជាមុខមាត់យ៉ាងណាទេ"។ "ឱឯងចង់យល់ចង់ស្គាហ្លួងនោះដែរឬអើ? " បានខ្ញុំបាទចង់ស្គាល់ដែរតែមិនដឹងជាហ្លួងនោះនៅឯណា អើបើឯងចង់ស្គាល់ហ្លួងនោះងាយទេ ចាំទៅដល់ទីជម្រំប្រជុំមនុស្សច្រើននោះកាលណា គេតែងតែដោះមួកគំនាប់ហ្លួង មនុស្សណាដែលមិនដោះមួកនោះមនុស្សនោះហើយជាហ្លួងពិតប្រាកដ ចូរឯងសំគាល់ថាជាហ្លួងចុះ"។ ឯក្មេងនោះបានឮដូច្នោះហើយ ក៏កំណត់កត់ចាំទុកក្នុងចិត្តលុះទៅដល់ទីទួលនោះ ឯបណ្តាលមុខមន្ត្រីទាំងឡាយបានឃើញស្តេចយាងទៅដល់ក៏នាំគ្នាត្រេកអរសាទរដោះមួកលើកដៃគំនាប់តាមទម្លាប់។

ឯមហាក្សត្រាធិបតី ស្តេចនាំកុមារនោះចុះចាកខ្នងមនោម័យដល់ហើយស្តេចបែរទៅនិយាយថា "ម្តេចឯងបានឃើញគេដោះមួកគំនាប់អ្នកណាៗ មិនដោះមួកគំនាប់គេនោះ? ក្មេងនោះតបថា "ហ្លួងនោះខ្ញុំស្គាល់ហើយ? "ចុះឯងថាអ្នកណាជាហ្លួង ចូរថាទៅមើល"។ "បាទ ហ្លួងនោះបើមិនរូបបងឯង គឺរូបខ្ញុំបាទ បើមិនខ្ញុំបាទក៏បងឯង ព្រោះមិនដោះមួកដូចគ្នា"។ ឯមហា

កុ្ដត្រាធិបតីបានស្តាប់កុមារនោះថ្លែងប្រាប់ ចេញមិនចំអង្គ
ទាគ្បៀវិយកទាំងរូបទាផងដូច្នោះហើយ ក៏ទ្រង់គិតថា ឯងបាន
ប្រាប់ទាថា "បើឃើញរូបណាមិនដោះមួកក្នុងកាលដែលប្រជុំ
ជន រូបនោះឯងគឺហួងហើយ ឥឡូវទាក៏មិនដោះ ឯងក៏មិនដោះ
ដូចគ្នា បានជាទាចង្អុលរូបទាំង២ ថាបើមិនឯងក៏ខ្លួនទា បើមិនទា
ក៏ឯងពាក្យទានោះជាពាក្យអ្នកឆោតខ្លៅ សំដៅត្រោះតែ
ប្រាប់ទេឬ ទាដឹងថាអញ្ជើនេះជាហួងហើយ បើទាដឹងច្បាស់ថា
អញ្ជើនេះជាហួងហើយតែទាចង់ថារូបទាផងត្រោះឯងប្រាប់មុន
នោះជាអាថ៌កំបាំងបន្តិច គឺថាអ្នកដែលមិនដោះមួក ទាក៏មិន
ដោះមួកដូចគ្នាទាអាអាទ័ដើមនេះ ទើបទាថាទាផងហេតុដូច្នោះ
ពាក្យទានោះបើពីត្រោះទៅ គួរទៅជាពាក្យអ្នកមានបញ្ញា
គឺជាពាក្យអ្នកប្រាជ្ញវិញបាន ពាក្យក្មេងយ៉ាងនេះ ត្បែមិន
ចេញជា ប្រាជ្ញឬជាខ្លៅក៏ថាមិនបាន" ។

ព្រះមហាកុ្ដត្រ ស្តេចទ្រង់គិតវិញទៀតឃើញថាពាក្យ
ក្មេងថានោះ គួរគិតយល់សេចក្តីថារូបស្តេចនេះនឹងសំដៅយក
ត្រង់មិនដោះមួក ជាប្រមាណនោះមិនបាន ឥស្សរតែមិនដោះ
មួកវិញក៏មាន ដែលហៅថាស្តេចៗនោះ គឺសំដៅយកចំណេះ

វិជ្ជាការដែលប្រកបដោយសង្គហវត្ថុ៤ ប្រការនឹងទ្រង់ទសពិធ
រាជធម៌ទាំង១០ ប្រការជាដើមទើបហៅថា ជាស្តេចជាហួងបាន
បើទោយកត្រង់មិនដោះមួកឬមិនលើកដៃគំនាប់តែ សន្មតថា
ជាមហាកុ្ដត្រនោះ ក្មេងដែលទាមិនដោះមួក មិនលើកដៃគំ
នាប់តែនោះ ក៏សន្មតថា មហាកុ្ដត្របានដូចគ្នា ទើបទាថាបើ
មិនឯងក៏អញ្ជើបើមិនអញ្ជើក៏ឯងយ៉ាងនេះ ។

១ទៀតដូចពាក្យហៅថា លោកសង្ឃនោះគឺសំដៅយកត្រង់
ទ្រទ្រង់គុណធម៌ ប្រកបដោយនូវសីលទាំង៤ មានបាតិមោក្ខសំ
វរសីលជាដើមផង ប្រកបដោយគុណធម៌របស់សមណៈ មាន
អប្បច្ឆតាទីគុណគឺប្រាថ្នាតិចមានចិត្តសន្តោស ជាដើមផងទើប
ហៅថាជាលោកសង្ឃបានក្នុងព្រះពុទ្ធសាសនានេះឯង បើទៅ
យកត្រង់កោរក្បាលត្រដោល ស្លៀកពាក់សម្តត់ពណ៌លឿងជា
ប្រមាណ ថាលោកសង្ឃនោះពួកបាសកក្មេងចាស់ ប្រុសស្រីមាន
តែកោរក្បាលត្រដោលដែរ ឯស្លៀកពាក់សម្តត់លឿងនោះក៏
មានដែរ ម្តេចពួកនោះក៏មិនសន្មតនាមហៅថា លោកសង្ឃទៅ
ផង ។ ពាក្យក្មេងគង្វាលក្របីទាថានោះ គួរយកជាគតិលោកបា
ន ហៅថាពាក្យបណ្ឌិតអ្នកប្រាជ្ញក្នុងលោកិយនេះបាន គួរឯង

ពិចារណាស្តាប់មើលចុះ។

និទាននេះមានដំណាលក្នុងក្បួនបារាំងសែស។

ចប់ភាគ ២ តែប៉ុណ្ណោះ។
